សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# សិទ្ធិ និងករណីយកិច្ចរបស់សហព័ទ្ធលើបំណុល

ស្រាវជ្រាវចាប់ពីថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២១ ដល់ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០២១

រៀបរៀងដោយ ៖
និស្សិតឈ្មោះ ៖ **យ៉ង់ រិទ្ធពេជ្រឆារ៉ូទ្ធិ**
**លី រតនា**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ព្រុំ រិទ្ធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២១ (សិក្សាបង់ថ្លៃ)

ឆ្នាំចូលសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំឈ្មោះ **លី រតនា** និង **យ៉ង់ រិទ្ធពេជ្រឆារ៉ូទ្ធិ** ជានិស្សិតឆ្នាំទី៤ ថ្នាក់ L4A3 នៃថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៧-២០២១។

## **សូមគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ**

**លោកឪពុកម្តាយ** និង **អ្នកម្តាយ** ដែលបានខិតខំបីបាច់ថែរក្សារូបកូនដោយសេចក្តីស្រឡាញ់ និងពោរពេញដោយទឹកចិត្តសន្តោសប្រណី ដែលមានតម្លៃមិនអាចកាត់ថ្លៃបាន តាំងពីតូចក្រូចឆ្មារហូតដល់កូនបានធំពេញវ័យ។ លោកទាំងពីររមែងតែងតែផ្តល់នូវដំបូន្មានល្អៗ និងបានអប់រំទូន្មានប្រៀនប្រដៅកូនឱ្យខិតខំកសាងខ្លួនក្លាយជាបុគ្គលដែលមានប្រយោជន៍សម្រាប់គ្រួសារ និងសង្គមជាតិទាំងមូល។ ដោយមានការប្រឹងប្រែងរបស់លោកទាំងពីរ ទើបធ្វើឱ្យកូនអាចឈានមកដល់ថ្ងៃនេះ។

ទន្ទឹមនឹងនេះយើងខ្ញុំសូមថ្លែងអំណរគុណចំពោះ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ ដែលបានបង្ហាត់បង្រៀន និងផ្តល់ចំណេះដឹងដល់សិស្សានុសិស្សទាំងអស់ តាំងពីបឋមសិក្សា រហូតដល់កម្រិតឧត្តមសិក្សា។ ម៉្យាងវិញទៀត យើងខ្ញុំក៏មិនភ្លេចអរគុណដល់ បងប្អូន-មិត្តនិស្សិត និងមិត្តភក្តិទាំងអស់ ដែលបានចូលរួមជួយគាំទ្រ និងលើកទឹកចិត្ត ហើយក៏បានជួយផ្តល់ជាយោបល់ល្អៗដល់យើងខ្ញុំ។

## **យើងខ្ញុំសូមថ្លែងអំណរគុណជាពិសេសចំពោះ**

**ឯកឧត្តមបណ្ឌិត លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែល **ឯកឧត្តមសាកលវិទ្យាធិការ** បានផ្តល់នូវឱកាសដល់ក្រុមយើងខ្ញុំធ្វើការស្រាវជ្រាវលើប្រធានបទខាងលើ និងទទួលបានឯកសារស្រាវជ្រាវល្អៗពីសាកលវិទ្យាល័យផងដែរ។

**បណ្ឌិត ព្រុំ រិទ្ធី** ដែលជាសាស្ត្រាចារ្យណែនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះ ហើយលោកបានចំណាយពេលវេលាយ៉ាងមានតម្លៃ ក្នុងការកែលម្អ និងផ្តល់ជាអនុសាសន៍ស្ថាបនាសម្រាប់ក្រុមយើងខ្ញុំក្នុងការសេរសេរសារណាតាំងពីដើមរហូតដល់បញ្ចប់ការស្រាវជ្រាវមួយនេះ ពិតជាមិនអាចមានអត្ថិភាពបានឡើយប្រសិនបើគ្មានការជ្រោមជ្រែងពីលោកគ្រូ។

ជាអវសានកថា យើងខ្ញុំទាំងពីរនាក់ សូមប្រសិទ្ធិពរជ័យ សិរីសួស្តី ជ័យមង្គលវិបុលសុខ មហាប្រសើរជូនដល់ លោកឪពុក អ្នកម្តាយ ឯកឧត្តម ថ្នាក់ដឹកនាំ លោកគ្រូអ្នកគ្រូ សាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បងប្អូន មិត្តនិស្សិត និងជនរួមជាតិទាំងអស់ឱ្យជួបប្រទះតែពុទ្ធិពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានធ្វើការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេល៤ឆ្នាំកន្លងមកនេះ ដោយបានខិតខំប្រឹងប្រែងក្នុងការរៀនសូត្រដើម្បីទទួលបាននូវចំណេះដឹងពី លោក លោកស្រី សាស្ត្រាចារ្យ នៅក្នុងសាកលវិទ្យាល័យ យើងខ្ញុំទាំងពីររូបត្រូវបានលើកទឹកចិត្ត និងទទួលបានការអនុញ្ញាតពីសាកលវិទ្យាល័យ ដើម្បីសរសេរសារណាបញ្ចប់ការសិក្សា ក្រោមប្រធានបទ "**សិទ្ធិ និងករណីយកិច្ចរបស់សហព័ទ្ធលើបំណុល**" នេះឡើង។

ដើម្បីរួមចំណែកក្នុងការយល់ឱ្យបានកាន់តែស៊ីជម្រៅអំពីសិទ្ធិ និងករណីយកិច្ចរបស់សហព័ទ្ធ យើងខ្ញុំដែលជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនិតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានរៀបចំនូវការសរសេរ ជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រ ដោយបានជ្រើសរើសប្រធានបទស្តីអំពី "**សិទ្ធិ និងករណីយកិច្ចរបស់សហព័ទ្ធលើបំណុល**" ដើម្បីចូលរួមចំណែកឱ្យប្រជាពលរដ្ឋកម្ពុជា ក៏ដូចជា បងប្អូន-មិត្តនិស្សិត បានយល់ច្បាស់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនលើបំណុលក្នុងនាមជាសហព័ទ្ធនៅក្នុងចំណងអាពាហ៍ពិពាហ៍ ក៏ដូចជាក្រោយការបញ្ចប់នៃចំណងអាពាហ៍ពិពាហ៍។ យើងខ្ញុំទាំងពីរនាក់សង្ឃឹមយ៉ាងមុតមាំថា ការចងក្រងសៀវភៅនេះនឹងអាចផ្តល់ជាអត្ថប្រយោជន៍បន្ថែមទៅដល់បងប្អូន មិត្តនិស្សិតជំនាន់ក្រោយ ក៏ដូចជាប្រជាពលរដ្ឋទូទៅដែលមានបំណងចង់ស្វែងយល់ និងជួយបង្កើនជាចំណេះដឹងរបស់ខ្លួនបន្ថែមទាក់ទងនឹងទំនាក់ទំនងរបស់សហព័ទ្ធក្នុងនីតិគ្រួសារ ឬអាចទុកជាឯកសារជំនួយសម្រាប់ការសិក្សាស្រាវជ្រាវនាពេលខាងមុខ។

ដោយហេតុថាអត្ថបទសិក្សាទាក់ទងនឹងប្រធានបទ "**សិទ្ធិ និងករណីយកិច្ចរបស់សហព័ទ្ធលើបំណុល**" អាចនឹងមានការកែប្រែមួយចំនួនលើលក្ខខណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាមួយចំនួន ដែលអាចនឹងនាំឱ្យមានការកែប្រែខ្លឹមសារខ្លះៗ។ ប៉ុន្តែយើងខ្ញុំនៅតែសង្ឃឹមយ៉ាងមុតមាំថាអត្ថបទសារណាបញ្ចប់ការសិក្សាមួយនេះ នឹងអាចយកមកធ្វើជាមូលដ្ឋានបានសម្រាប់ការសិក្សាស្រាវជ្រាវនាពេលបច្ចុប្បន្ន និងនៅពេលអនាគត។ យ៉ាងណាមិញដើម្បីបំពេញបន្ថែមនូវចំណុចខ្វះខាតបងប្អូន-មិត្តអ្នកអាន ក៏ចូលរួមក្នុងការកែលំអក្នុងន័យស្ថាបនាក្នុងអត្ថបទស្រាវជ្រាវនេះបានដែរ។

ជាចុងក្រោយយើងខ្ញុំសូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅដល់អ្នកទាំងអស់គ្នាដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការអាន និងស្វែងយល់អំពីស្នាដៃរបស់យើងខ្ញុំ។ យើងខ្ញុំគោរពជូនពរ និងសូមប្រសិទ្ធិពរជ័យជូនដល់បងប្អូន មិត្តអ្នកអាន និងប្រជាពលរដ្ឋកម្ពុជាទាំងមូលឱ្យជួបប្រទះតែសំណាងល្អ និងសមប្រកបក្នុងមុខរបរទទួលទានប្រចាំថ្ងៃ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១

១. លំនាំបញ្ហា ........ ១

២. ចំណោទបញ្ហា ........ ២

៣. គោលបំណង ........ ២

៤. ដែនកំណត់ និងវិសាលភាព ........ ២

៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣

៦. វិធីសាស្ត្រស្រាវជ្រាវ ........ ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣

**ជំពូកទី១**

**ចំណាត់ថ្នាក់បំណុល**

១. បំណុលរួម ........ ៤

២. បំណុលដោយឡែក ........ ៧

**ជំពូកទី២**

**សិទ្ធិ និងករណីយកិច្ចរបស់សហព័ទ្ធលើបំណុលរួម**

១. ការបាត់ខ្លួនរបស់សហព័ទ្ធ ........ ៩

២. ការបំបែកលំនៅសង្វាសតាមអង្គហេតុ ........ ១១

៣. សហព័ទ្ធជាអសមត្ថជន ........ ១៣

៤. ការលែងលះ ........ ១៤

៥. សហព័ទ្ធជាពាណិជ្ជករ ........ ១៧

៦. សហព័ទ្ធជាជនបរទេស ........ ២១

៧. របបសន្តតិកម្ម ........ ២៣

**សេចក្តីសន្និដ្ឋាន** ........ ២៨

**អនុសាសន៍** ........ ៣០

**ឯកសារយោង**

**ឧបសម្ព័ន្ធទី១**

**ឧបសម្ព័ន្ធទី២**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

កាលដើមឡើយ មនុស្សរស់នៅជាមួយគ្នាតាមបែបធម្មជាតិ ហើយនៅពេលដែលមានជម្លោះកើតឡើង ពួកគេតែងតែយោគយល់ និងអត់ឱនឱ្យគ្នាទៅវិញទៅមក ប៉ុន្តែយើងក៏សង្កេតឃើញថាក្នុងកាលៈទេសៈខ្លះមនុស្ស បានប្រើប្រាស់ច្បាប់ព្រៃមកដោះស្រាយបញ្ហាផងដែរ។ ការវិវត្តរបស់មនុស្សពីមួយសម័យកាលទៅមួយសម័យកាល បានបង្កើតឱ្យមានការចងភ្ជាប់នឹងគ្នា រហូតមកដល់បច្ចុប្បន្ននេះ ការចងភ្ជាប់នេះបានបង្កើតជាចំណងគតិយុត្ត ដែលធ្វើឱ្យមានភាពកាន់តែល្អប្រសើរ និងមានលក្ខណៈត្រឹមត្រូវតាមបរិបទនៃសង្គមនីមួយៗ។ ការបង្កើតច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ គឺធ្វើឡើងក្នុងគោលបំណងធានាការរស់នៅឱ្យមានភាពយុត្តិធម៌ តម្លាភាព និងបញ្ចៀសនូវរាល់បញ្ហាដែលអាចកើតមានឡើងទាំងក្នុងពេលបច្ចុប្បន្ន និងពេលអនាគត។

ក្នុងឆាកជីវិតមនុស្សម្នាក់ៗតែងតែឆ្លងកាត់នូវការរៀបអាពាហ៍ពិពាហ៍។ អាពាហ៍ពិពាហ៍គឺជាចំណងគតិយុត្តមួយរវាងបុរស និងនារីដែលបានរួមរស់ជាមួយគ្នា ជាប្តីប្រពន្ធស្របច្បាប់ ដែលត្រូវបំពេញគ្រប់លក្ខខណ្ឌ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ ក្នុងទំហំដែលច្បាប់បានកំណត់។[1] តាមរយៈអាពាហ៍ពិពាហ៍នេះហើយ ទើបបុរស និងនារីនោះបានភ្ជាប់នូវទំនាក់ទំនងញាតិនឹងគ្នាដោយស្របច្បាប់[2] ក្រោមរូបភាពនៃការចុះសំបុត្រអាពាហ៍ពិពាហ៍។ ក្រោយពេលដែលបុរស និងនារីសម្រេចចិត្តរៀបអាពាហ៍ពិពាហ៍ និងកសាងអនាគតជាមួយគ្នាហើយ គឺបង្កើតឱ្យមានចំណងគតិយុត្តជាច្រើនជាមួយគ្នា មានដូចជាកូនរួមគ្នា ទ្រព្យសម្បត្តិរួមគ្នា និងបំណុលរួមគ្នាផងដែរ។ ដោយសម្លឹងឃើញពីបញ្ហាជាច្រើនដែលភាគច្រើនគឺកើតចេញពីទំនាក់ទំនងទ្រព្យសម្បត្តិក្នុងគ្រួសារទាំងមុន និងក្រោយពេលរៀបអាពាហ៍ពិពាហ៍ ព្រមទាំងបញ្ហាដែលកើតមានឡើងអំឡុងពេលបាត់ខ្លួន, អវត្តមានរបស់សហព័ទ្ធម្ខាង, សហព័ទ្ធប្រែជាអសមត្ថជន និងបញ្ហាក្រោយពេលលែងលះក៏បានក្លាយជាបញ្ហាចោទសម្រាប់ភាគីម្ខាងទៀតផងដែរ ទាក់ទងនឹងការគ្រប់គ្រងលើប្រព័ន្ធទ្រព្យសម្បត្តិក្នុងគ្រួសារ និងការទូទាត់បំណុលផងដែរ។ ហេតុនេះប្រធានបទ ៖ "**សិទ្ធិ និងករណីយកិច្ចរបស់សហព័ទ្ធលើបំណុល**" នឹងមានការលើកឡើងពីបញ្ហាប្រឈមភាពខ្វះចន្លោះ និងដំណោះស្រាយនានានៃការអនុវត្ត ក្នុងការដោះស្រាយវិវាទ ដែលទាក់ទងទៅនឹងទំនាក់ទំនងសិទ្ធិ និងករណីយកិច្ចរបស់សហព័ទ្ធក្នុងប្រព័ន្ធ នៃច្បាប់ទាំងឡាយដែលមានជាធរមាននៅព្រះរាជាណាចក្រកម្ពុជា ដែលមានភាពទាក់ទងទៅនឹងចំណងអាពាហ៍ពិពាហ៍របស់សហព័ទ្ធ។

ជាការឆ្លើយតបនឹងបញ្ហាចោទទាក់ទងនឹងវិវាទខាងលើ កិច្ចការស្រាវជ្រាវនេះបានជ្រើសរើសឯកសារជាមូលដ្ឋានមួយចំនួនដើម្បីសរសេរសារណានេះឡើង ដែលឯកសារទាំងនោះរួមមាន រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រ

---

[1] ក្រមរដ្ឋប្បវេណី, នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៤៨ ដល់ មាត្រា ៩៥២ (ពីពេលនេះទៅហៅថា ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧)។

[2] មាត្រា ៩៣៨ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

កម្ពុជា (២៤ កញ្ញា ១៩៩៣) ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា (២១ ធ្នូ ២០០៧) ច្បាប់ស្ដីពីឯកពន្ធភាព (២១ តុលា ២០០៦-និរាករណ៍) ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ (២០ កក្កដា ១៩៨៩-និរាករណ៍) ច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម (១៨ វិច្ឆិកា ១៩៩៥) ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម (១៩ មិថុនា ២០០៥) ច្បាប់ភូមិបាល ( ៣០ សីហា ២០០១) ច្បាប់ស្ដីសញ្ជាតិ (២១ មិថុនា ២០១៨) ព្រមទាំងសេចក្ដីកំណត់ នៃក្រមរដ្ឋប្បវេណី ភាគ១ គន្ថីទី១ ដល់គន្ថីទី៣, ភាគ៥ គន្ថីទី៧ និងភាគី៦ គន្ថីទី៨ ដល់ទី៩។

## ២. ចំណោទបញ្ហា

តើអ្វីទៅជាទ្រព្យសម្បត្តិរបស់សហព័ទ្ធ ដែលមាននៅក្នុងចំណងអាពាហ៍ពិពាហ៍ក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា? តើទ្រព្យសម្បត្តិប្ដីប្រពន្ធនៅក្នុងចំណងអាពាហ៍ពិពាហ៍ អាចត្រូវបែងចែកជាប៉ុន្មានប្រភេទ? តើបំណុលរបស់សហព័ទ្ធ អាចត្រូវបែងចែកជាប៉ុន្មានប្រភេទ? តើសហព័ទ្ធអាចប្រើប្រាស់ទ្រព្យទាំងនោះទៅដោះស្រាយបំណុលដោយរបៀបណាខ្លះ? តើសហព័ទ្ធមានសិទ្ធិ និងករណីយកិច្ចដូចម្ដេចខ្លះទៅលើបំណុល? ប្រសិនបើមានបញ្ហាណាមួយកើតឡើងពាក់ព័ន្ធនឹងការទូទាត់បំណុលក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬក្រោយពេលលែងលះ ឬក្រោយពេលចាប់ផ្ដើមនូវរបបសន្តតិកម្ម តើនឹងដោះស្រាយយ៉ាងដូចម្ដេងទៅលើបំណុលនោះ?

## ៣. គោលបំណង

គោលបំណងនៃប្រធានបទមួយនេះ គឺដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់ពីបញ្ហាចោទដែលកើតមានឡើងពាក់ព័ន្ធនឹងបំណុលរបស់សហព័ទ្ធ ដែលរួមមានសិទ្ធិ និងករណីយកិច្ចរបស់សហព័ទ្ធក្នុងប្រព័ន្ធនៃនីតិគ្រួសារ។ លើសពីនេះការស្រាវជ្រាវលើប្រធានបទនេះ ក៏បានលើកឡើងអំពីដំណោះស្រាយនានាលើបញ្ហាប្រឈមទាំងឡាយដែលអាចកើតមានឡើងក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬក្រោយពេលលែងលះ ឬបន្ទាប់ពីពេលចាប់ផ្ដើមនូវរបបសន្តតិកម្ម ដែលទាក់ទងនឹងការទូទាត់បំណុល។

ទោះបីជាមានបញ្ញត្តិច្បាប់បានកំណត់ក៏ពិតមែន ប៉ុន្តែវានៅតែមានចំណុចខ្លះដែលខ្វះខាត ឬធ្វើឱ្យអ្នកច្បាប់មួយចំនួនមានការលំបាកក្នុងការស្វែងរកដំណោះស្រាយ នៅពេលដែលជួបប្រទះបញ្ហាណាមួយថ្មីដែលមិនធ្លាប់កើតមានឡើង។ ហេតុនេះការស្រាវជ្រាវលើប្រធានបទខាងលើ អាចផ្ដល់ជាជំនួយស្មារតី ឬដំណោះស្រាយថ្មីខ្លះៗដល់បងប្អូនសិស្ស-និស្សិតជំនាន់ក្រោយ ក្នុងការដោះស្រាយវិវាទដែលអាចកើតមានឡើង និងអាចប្រើប្រាស់ជាឯកសារជំនួយក្នុងការស្រាវជ្រាវទៅថ្ងៃអនាគតផងដែរ។ ម្យ៉ាងវិញទៀត ឯកសារនេះក៏អាចឱ្យប្រជាពលរដ្ឋកម្ពុជាបានជ្រួតជ្រាបពីស្ថានភាពនៃការអនុវត្តច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ។

## ៤. ដែនកំណត់ និងវិសាលភាព

ប្រធានបទនេះ បង្ហាញអំពី ទ្រព្យសម្បត្តិដែលសហព័ទ្ធមាន ដែលអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្ន និងដែលមានដែនកំណត់ក្នុងរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ អំពី

ប្រភេទនៃបំណុលដែលសហព័ទ្ធមាន ព្រមទាំងដំណោះស្រាយចំពោះការទូទាត់បំណុលក្នុងលក្ខខណ្ឌនីមួយៗដែលច្បាប់បានកំណត់។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

សារៈសំខាន់នៃប្រធានបទនេះ គឺចែករំលែកចំណេះដឹងដល់មិត្តនិស្សិត និងប្រជាជនទាំងអស់ឱ្យបានយល់ច្បាស់អំពីបំណុលរបស់ប្តីប្រពន្ធ និងការទូទាត់បំណុលតាមគោលការណ៍ច្បាប់។ ដោយយល់ឃើញថា ប្រជាជនមួយចំនួននៅមានភាពស្រពិចស្រពិលទៅលើបំណុល ក៏ដូចជាករណីយកិច្ចលើបំណុល ទើបធ្វើឱ្យមានបញ្ហាកើតមានឡើងជាច្រើន ជាពិសេសបំណុលរបស់សហព័ទ្ធតែម្តង។

សារៈសំខាន់មួយទៀត គឺដើម្បីឱ្យមានតម្លាភាពចំពោះបំណុលរបស់សព័ទ្ធ និងចូលរួមកាត់បន្ថយនូវវិវាទដែលកើតមានឡើងចំពោះការមិនអនុវត្តកាតព្វកិច្ចលើបំណុលផងដែរ។ ប្រសិនបើទទួលបានជោគជ័យមែននោះប្រព័ន្ធច្បាប់ដែលអនុវត្តទៅលើបំណុលនឹងមានភាពកាន់តែល្អប្រសើរ។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ប្រធានបទខាងលើនេះ នឹងមានការលើកយកមកបង្ហាញនូវប្រភពឯកសារគ្រប់ទម្រង់ទាំងអស់រួមទាំងឯកសារច្បាប់ ឯកសារជាសៀវភៅបោះពុម្ភ រួមផ្សំជាមួយឯកសារពីបណ្តាញផ្សព្វផ្សាយអ៊ីនធើណេត ក្នុងការបង្កើតជាឯកសារស្រាវជ្រាវនេះឡើង។ ការវិភាគលើឯកសារច្បាប់ដោយផ្អែកលើអត្ថិភាពជាធរមាននៃច្បាប់ដែលកំពុងមានអានុភាពអនុវត្ត រួមបញ្ចូលទាំង រដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សាលដីកា សាលក្រម និងបទដ្ឋានគតិយុត្តនានាដែលកំពុងអនុវត្តលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ប្រធានបទស្រាវជ្រាវ "**សិទ្ធិ និងករណីយកិច្ចរបស់សហព័ទ្ធលើបំណុល**" នឹងមានការលើកមកបង្ហាញនូវពីរជំពូកសំខាន់ៗគឺ ៖

- **ជំពូកទី១. ចំណាត់ថ្នាក់បំណុល** ៖ នឹងមានការលើកបង្ហាញអំពីប្រភេទនៃបំណុលរបស់សហព័ទ្ធដែលរួមមានបំណុលដោយឡែក និងបំណុលរួម ដោយផ្អែកទៅលើទ្រព្យរបស់សហព័ទ្ធ។
- **ជំពូកទី២. សិទ្ធិ និងករណីយកិច្ចរបស់សហព័ទ្ធលើបំណុលរួម** ៖ នឹងមានការបកស្រាយអំពីសិទ្ធិ និងករណីយកិច្ចរបស់សហព័ទ្ធលើបំណុលរួម ដែលមានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ និងសិក្សាអំពីលក្ខខណ្ឌក្នុងការឆ្លើយតបបំណុលក្នុងករណីនីមួយៗរួមមាន ១. ការបាត់ខ្លួនរបស់សហព័ទ្ធ, ២. ការបំបែកលំនៅសង្វាសតាមអង្គហេតុ, ៣. សហព័ទ្ធជាអសមត្ថជន, ៤. ការលែងលះ, ៥. សហព័ទ្ធជាពាណិជ្ជករ, ៦. សហព័ទ្ធជាជនបរទេស, ៧. របបសន្តតិកម្ម។

# ជំពូកទី១

# ចំណាត់ថ្នាក់បំណុល

ក្រោយពីបង្កើតចំណងអាពាហ៍ពិពាហ៍រួចហើយ ចំណងគតិយុត្តនៃទំនាក់ទំនងរបស់សហព័ទ្ធក៏ត្រូវបានចាប់ផ្តើមឡើង ដែលបង្កើតឱ្យមានសិទ្ធិ និងករណីយកិច្ចរបស់សហព័ទ្ធលើបំណុលផងដែរ ហើយបំណុលនៅក្នុងន័យនេះ គឺសម្តៅទៅលើបំណុលរួម និងបំណុលដោយឡែករបស់សហព័ទ្ធដែលមានមុនពេល និងក្រោយពេលរៀបអាពាហ៍ពិពាហ៍ ក៏ដូចជាការបន្សល់ទុកនូវបំណុលបន្ទាប់ពីការលែងលះ ដែលនឹងត្រូវបកស្រាយលម្អិតដូចខាងក្រោម ៖

## ១. បំណុលរួម

តាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិអំពីសិទ្ធិ និងករណីយកិច្ចរបស់សហព័ទ្ធទាក់ទងនឹងការប្រើប្រាស់, ការគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិរួមនៅក្នុងទំនាក់ទំនងអាពាហ៍ពិពាហ៍ និងសិទ្ធិបែងចែកទ្រព្យសម្បត្តិរួមនៅពេលលែងលះ។ ទន្ទឹមនឹងនោះផងដែរ ច្បាប់ក៏បានបញ្ញត្តិអំពីបំណុល ឬកាតព្វកិច្ចផ្សេងទៀតរបស់សហព័ទ្ធដែលកើតមានឡើងក្នុងអំឡុងពេលនៃចំណងអាពាហ៍ពិពាហ៍ ដោយកំណត់ឱ្យសហព័ទ្ធត្រូវទទួលខុសត្រូវរួមគ្នា ចំពោះបំណុលរួមផងដែរ។ តើអ្វីទៅជាបំណុលរួម?

បំណុលរួម គឺជាសោហ៊ុយចំណាយផ្សេងៗដូចជា ៖ ១. សោហ៊ុយដើម្បីរក្សាជីវភាពរួមរបស់ប្តីប្រពន្ធ និងសោហ៊ុយដើម្បីការអប់រំ ឬការព្យាបាល ថែទាំកូនជាអាទិ៍ , ២. បំណុលដែលប្តី ឬប្រពន្ធទាំងសងខាងបានព្រមព្រៀងតាមលិខិតជាលាយល័ក្ខណ៍អក្សរ ជាមួយម្ចាស់បំណុល នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬបំណុលដែលប្តី ឬប្រពន្ធតែម្ខាង បានខ្ចីពីម្ចាស់បំណុលដោយមានការយល់ព្រមតាមលិខិតជាលាយល័ក្ខណ៍អក្សរពីប្តី ឬប្រពន្ធម្ខាងទៀត នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ , ៣. សោហ៊ុយដើម្បីគ្រប់គ្រង និងរក្សាទ្រព្យសម្បត្តិរួម។[3] មាត្រានេះចែងអំពីករណីដែលថា ទោះបីជាកម្ពុជាអនុម័តយកប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធក៏ដោយ ក៏ពុំមានភាពសមរម្យក្នុងការដាក់បន្ទុកឱ្យប្តីប្រពន្ធនីមួយៗនូវកាតព្វកិច្ចដ៏ធ្ងន់ធ្ងរដែរ ហើយមានភាពសមរម្យឱ្យទទួលខុសត្រូវចំពោះកាតព្វកិច្ចរួមគ្នាក្នុងទំហំសមរម្យមួយ ដែលទោះបីជាមើលពីខាងតតិយជនទៅ ក៏ឃើញថា សមរម្យដែរ។[4]

សោហ៊ុយដើម្បីរក្សាជីវភាពរួមរបស់ប្តីប្រពន្ធ និងសោហ៊ុយដើម្បីការអប់រំ ឬការព្យាបាល ថែទាំកូន គឺជាបំណុលរួមដែលប្តីប្រពន្ធទាំងសងខាងមានកាតព្វកិច្ចសាមគ្គីភាពក្នុងការទទួលខុសត្រូវលើបំណុលនេះ។[5]

**ឧទាហរណ៍ ៖** ប្តីបានចាកចេញពីផ្ទះទៅរស់នៅជាមួយស្រីកំណាន់ ហើយក៏មិនបានផ្តល់ប្រាក់ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារដែរ។ ចំណែកប្រពន្ធត្រូវទទួលខុសត្រូវចំពោះការចំណាយទាំងអស់នៅក្នុងផ្ទះ ជាពិសេសថ្លៃឈ្នួលផ្ទះ

[3] មាត្រា ៩៧៥ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[4] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគ៥ គន្ថីទី៧, ទំព័រទី៣៥។

[5] មាត្រា ៩៧៥ ចំណុច ក ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

ជារៀងរាល់ខែ។ ដោយសារជីវភាពជួបបញ្ហា ប្រពន្ធបានខ្ចីប្រាក់ពីបងស្រីរបស់ខ្លួនចំនួន ២.០០០ ដុល្លារ ប្រាក់នោះត្រូវបានចំណាយសម្រាប់ថ្លៃឈ្នួលផ្ទះក្នុងមួយខែចំនួន ៣០០ ដុល្លារ រយៈពេល៣ ខែ ស្មើនឹងចំនួន ៩០០ ដុល្លារ ហើយបានទិញម៉ូតូមួយគ្រឿងសម្រាប់ជិះទៅធ្វើការ និងជូនកូនទៅសាលារៀន (ម៉ូតូចាស់បានខូច) ក្នុងតម្លៃ ៥០០ ដុល្លារ និងប្រាក់ចំនួន ៦០០ ដុល្លារទៀត សម្រាប់ការចំណាយថ្លៃទឹក-ភ្លើង អាហារហូបចុកប្រចាំថ្ងៃ។ ចំពោះបំណុលចំនួន ២.០០០ ដុល្លារ ដែលប្រពន្ធជាអ្នកខ្ចីពីបងស្រី ត្រូវបានរាប់បញ្ចូលជាសោហ៊ុយសម្រាប់កិច្ចការគ្រួសារ ដែលច្បាប់កំណត់ថាជាបំណុលរួម ហើយប្តីប្រពន្ធត្រូវទទួលខុសត្រូវរួមគ្នា ទោះបីជាប្រពន្ធជាអ្នកខ្ចីតែម្នាក់ឯងក៏ដោយ។ ក្នុងករណីនេះប្តីមិនអាចបដិសេធថាខ្លួនមិនដឹងពីរឿងនេះ, ខ្លួនមិនមែនជាអ្នកខ្ចី ព្រោះវាជាបំណុលរួម។[6]

បំណុលដែលប្តីប្រពន្ធទាំងសងខាង បានព្រមព្រៀងតាមលិខិតជាលាយល័ក្ខណ៍អក្សរជាមួយម្ចាស់បំណុលនៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬបំណុលដែលប្តី ឬប្រពន្ធតែម្ខាង បានខ្ចីពីម្ចាស់បំណុលដោយមានការយល់ព្រមតាមលិខិតជាលាយល័ក្ខណ៍អក្សរពីប្តី ឬប្រពន្ធម្ខាងទៀត នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។[7] ចំណុចនេះទាមទារជាពិសេសឱ្យមានលក្ខខណ្ឌចាំបាច់នៃលិខិតជាលាយល័ក្ខណ៍អក្សរ និងការព្រមព្រៀងរវាងប្តីប្រពន្ធទាំងសងខាង ដើម្បីជៀសវាងការដាក់បន្ទុកធ្ងន់ធ្ងរទៅដល់ភាគីម្ខាងៗ។[8]

**ឧទាហរណ៍ ៖** ប្តី និងប្រពន្ធ បានចុះកិច្ចសន្យាទិញផ្ទះក្នុងតម្លៃ ១០០.០០០ ដុល្លារ ដោយប្រើប្រាស់លុយរួម (ទ្រព្យរួម) ចំនួន ៨០.០០០ ដុល្លារ និងប្រាក់ចំនួន ២០.០០០ ដុល្លារទៀត (ខ្ចីធនាគារ)។ ប្តីប្រពន្ធ បានចុះកិច្ចសន្យាខ្ចីប្រាក់ ដោយធ្វើជាលាយល័ក្ខណ៍អក្សរជាមួយធនាគារ។ ក្នុងករណីនេះបំណុលដែលប្តីប្រពន្ធជំពាក់ធនាគារចំនួន ២០.០០០ ដុល្លារ គឺជាបំណុលរួម ដែលប្តីប្រពន្ធទាំងសងខាង បានព្រមព្រៀងគ្នាបង្កើត ហេតុនេះប្តីប្រពន្ធត្រូវទទួលខុសត្រូវចំពោះបំណុលរបស់ធនាគារដោយរួមគ្នា។

**ឧទាហរណ៍ ៖** លោកស្រី **ក** និងលោក **ខ** បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។ ក្នុងអំឡុងពេលរស់នៅជាមួយគ្នា លោកស្រី **ក** និង លោក **ខ** មានកូនចំនួន០២ នាក់ ដោយសារតែលោកស្រី **ក** និងលោក **ខ** ចេះតែមានទំនាស់ក្នុងគ្រួសារមិនអាចសម្របសម្រួលគ្នាបាន ទើបធ្វើឱ្យមានោសញ្ចេតនាក្នុងការរស់នៅជាប្តីប្រពន្ធ រហូតឈានដល់ការដាក់ពាក្យបណ្តឹងសុំលែងលះមកតុលាការ។ ចំពោះទ្រព្យសម្បត្តិរួម និងបំណុលរួម សុំឱ្យតុលាការបែងចែកតាមការព្រមព្រៀង។[9] ក្នុងអង្គហេតុខាងលើនេះ តុលាការបានចេញសេចក្តីសម្រេចបញ្ចប់ និងប្រកាសជាសាធារណៈដោយសម្រេចឱ្យលោកស្រី **ខ** ជាអ្នកទទួលបន្ទុកតែម្នាក់លើបំណុលជំពាក់ធនាគារ ស្របតាមការកម្មវត្ថុនៃការព្រមព្រៀងរបស់ភាគី។

[6] ឈុំ មុនីសុជាតា មេធាវីនៃក្រុមមេធាវី ជេ ស៊ី និងជាសមាជិកវិភាគទានច្បាប់, ការទទួលខុសត្រូវចំពោះបំណុលរួមរបស់ប្តីប្រពន្ធ, ១៦ មីនា ឆ្នាំ២០២១, គេហទំព័រ https://ciclg.com/kh/article/215, ចូលទស្សនាថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២១។

[7] មាត្រា ៩៧៥ ចំណុច ខ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[8] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគ៥ គន្ថីទី៧, ទំព័រទី៣៥។

[9] សាលក្រមរដ្ឋប្បវេណីលេខ ១១១១ "ឃ" ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ។

សោហ៊ុយដើម្បីគ្រប់គ្រង និងរក្សាទ្រព្យសម្បត្តិរួម។[10] **ឧទាហរណ៍ ៖** ផ្ទះដែលជាទ្រព្យរួមរបស់ប្ដីប្រពន្ធ ត្រូវបានរងការខូចខាតដោយសារទឹកលិចនៅរដូវវស្សា មានភាពចាំបាច់ត្រូវជួសជុល ហើយប្រពន្ធបានឱ្យជាងជួសជុលដោយចំណាយប្រាក់អស់ ៧.០០០ ដុល្លារ។ ប៉ុន្តែក្រោយបញ្ចប់ការជួសជុល ប្រពន្ធបង់ប្រាក់ឱ្យជាងមិនគ្រប់ចំនួនទេ នៅខ្វះចំនួន ២.០០០ ដុល្លារទៀត។ ក្នុងករណីនេះ កាតព្វកិច្ចចំនួន ២.០០០ ដុល្លារ គឺជាសោហ៊ុយដើម្បីថែរក្សាទ្រព្យសម្បត្តិរួម ហេតុនេះជាបំណុលរួមដែលប្ដីប្រពន្ធត្រូវទទួលខុសត្រូវរួមគ្នា។

ចំពោះបំណុល ឬកាតព្វកិច្ចផ្សេងទៀត ដែលប្ដី ឬប្រពន្ធតែម្ខាង ជាអ្នកបង្កើត ដែលមិនពាក់ព័ន្ធនឹងសោហ៊ុយដើម្បីរក្សាជីវភាពរួមជាអាទិ៍ ឬការគ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិរួម មិនមែនជាបំណុលរួមទេ ហើយមិនអាចទាមទារឱ្យប្ដីប្រពន្ធទទួលខុសត្រូវរួមគ្នានោះទេ ពោលគឺត្រូវទទួលខុសត្រូវរៀងៗខ្លួន (អ្នកណាជាអ្នកបង្កើតកាតព្វកិច្ច/បំណុល អ្នកនោះជាអ្នកទទួលខុសត្រូវ)។ ក្រមរដ្ឋប្បវេណីបារាំង ក៏ចែងដែរថា ម្ចាស់បំណុល ជាគោលការណ៍ គ្មានសិទ្ធិប្រមូលបំណុលពីទ្រព្យដោយឡែករបស់សហព័ទ្ធរបស់កូនបំណុលទេ ក៏ប៉ុន្តែ ទោះបីជាសហព័ទ្ធតែម្ខាងទទួលនូវកាតព្វកិច្ចក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ក៏ដោយ ប្រសិនបើកាតព្វកិច្ចនោះពាក់ព័ន្ធនឹងផលប្រយោជន៍គ្រួសារ កាតព្វកិច្ចនោះជាបន្ទុករបស់ទ្រព្យសម្បត្តិរួម ហើយប្រសិនបើកាតព្វកិច្ចនោះជាផលប្រយោជន៍ឯកជនរបស់សហព័ទ្ធតែម្ខាងទេ សហព័ទ្ធនោះត្រូវទទួលបន្ទុកតែម្នាក់ឯង។[11]

**ឧទាហរណ៍ ៖** ប្ដីកំពុងមានស្នេហាលួចលាក់ជាមួយស្រីកំណាន់របស់ខ្លួន ហើយដោយសារចង់យកចិត្តយកថ្លើមស្រីកំណាន់ ប្ដីបានខ្ចីប្រាក់ពីមិត្តភក្ដិរបស់ខ្លួនចំនួន ៣.០០០ ដុល្លារ ដើម្បីទិញចិញ្ចៀនពេជ្រមួយវង់ឱ្យស្រីកំណាន់។ បំណុលចំនួន ៣.០០០ ដុល្លារ ជាបំណុល ដែលកើតពីអំពើសាវ៉ារបស់ប្ដី ហើយប្ដីចុះកិច្ចសន្យាតែម្នាក់ឯង ហេតុនេះ បំណុលនោះមិនមែនជាបំណុលរួមទេ គឺជាបំណុលដែលឡែកនាំឱ្យប្ដីត្រូវទទួលខុសត្រូវតែម្នាក់ឯង។

ប៉ុន្តែក្នុងករណីដែលប្ដីបានធ្វើការចាត់ចែងទ្រព្យសម្បត្តិរួម ដើម្បីបានប្រាក់យកទៅដោះស្រាយបំណុលដែលខ្លួនបានជំពាក់ ដោយគ្មានការយល់ព្រមពីប្រពន្ធ និងគ្មានការអនុញ្ញាតពីតុលាការនោះ ច្បាប់អនុញ្ញាតឱ្យប្រពន្ធដែលមិនបានផ្ដល់ការយល់ព្រមនោះ ប្ដឹងទៅតុលាការដើម្បីសុំមោឃភាពនូវការចាត់ចែងទ្រព្យដែលប្ដីបានធ្វើកន្លងមកនោះ។ បញ្ញត្តិនេះផ្ដល់ការសង្គ្រោះដល់សហព័ទ្ធដែលមិនផ្ដល់ការយល់ព្រមឱ្យសហព័ទ្ធម្ខាងទៀតធ្វើការចាត់ចែងទ្រព្យសម្បត្តិរួមដោយឯកតោភាគី ជាពិសេសចំពោះអចលនវត្ថុសម្រាប់ការអាស្រ័យនៅរបស់គ្រួសារ។ មាត្រា ១៣៦៩ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ រាល់ការចាត់ចែងរបស់របរសម្រាប់ប្រើក្នុងផ្ទះទាំងឡាយ ចាំបាច់ត្រូវមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត ហើយប្រសិនបើគ្មានការយល់ព្រមទេ ការចាត់ចែងត្រូវចាត់ទុកជាមោឃៈ។ មាត្រា ១១០០ នៃក្រមគ្រួសាររបស់រដ្ឋកាលីហ្វ័រញ៉ាចែងថា សហព័ទ្ធនីមួយៗ មានសិទ្ធិគ្រប់គ្រងដោយឯករាជ្យនូវចលនវត្ថុដែលជាទ្រព្យរួម ប៉ុន្តែមិនអាចលក់ ឬធ្វើអនុប្បទាន ឬធ្វើការចាត់ចែងផ្សេងទៀតនូវគ្រឿងសង្ហារឹម ឬរបស់

[10] មាត្រា ៩៧៥ ចំណុច គ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[11] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគ៥ គន្ថីទី៧, ទំព័រទី៣៥។

បរក្នុងផ្ទះដោយគ្មានការអនុញ្ញាត ឬយល់ព្រមជាលាយល័ក្ខណ៍អក្សរពីសហព័ទ្ធម្ខាងទៀតទេ ក៏ប៉ុន្តែចំពោះអចលនវត្ថុដែលជាទ្រព្យរួម សហព័ទ្ធអាចទាមទារទៅតុលាការឱ្យចេញដីកាសម្រេចឱ្យបន្ថែមឈ្មោះសហព័ទ្ធដែលមិនមានឈ្មោះក្នុងបញ្ជីកម្មសិទ្ធិ ទៅក្នុងបញ្ជី ឬលិខិតបញ្ជាក់សិទ្ធិ។ លើសពីនេះវាផ្តល់ការងាយស្រួលដល់តតិយជនដែលជាភាគីអ្នកទិញមិនពិបាកក្នុងការស្រាវជ្រាវបញ្ជាក់ថា មានសហព័ទ្ធដែលមិនមានឈ្មោះក្នុងបញ្ជីកម្មសិទ្ធិនោះទេ។[12]

## ២. បំណុលដោយឡែក

បំណុលដោយឡែក គឺជាបំណុលដែលសហព័ទ្ធមានមុនពេលរៀបអាពាហ៍អាពាហ៍ និងអាចមាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ផងដែរ ពោលគឺសហព័ទ្ធចុះកិច្ចសន្យាទទួលខុសត្រូវលើបំណុលតែម្នាក់ឯងដោយពុំមានការព្រមព្រៀងពីសហព័ទ្ធម្ខាងទៀត ដែលបំណុលនោះមិនមែនក្នុងគោលបំណងដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ ឬដោះស្រាយភាពចាំបាច់នៅក្នុងគ្រួសារនោះទេ។ ហេតុដូចនេះបំណុលដោយឡែក គឺសហព័ទ្ធតែម្ខាងត្រូវតែទទួលខុសត្រូវលើបំណុលនោះតែម្នាក់ឯង ដោយត្រូវយកទ្រព្យសម្បត្តិដោយឡែកដែលខ្លួនមានយកទៅឆ្លើយតបទៅនឹងបំណុលដែលខ្លួនបានជំពាក់ ចំណែកឯសហព័ទ្ធម្ខាងទៀតពុំមានកាតព្វកិច្ចលើបំណុលដោយឡែករបស់សហព័ទ្ធដែលបានសម្រេចដោយឯកតោភាគីនោះទេ ហើយចំពោះទ្រព្យសម្បត្តិរួមវិញ គឺសហព័ទ្ធមិនអាចធ្វើការចាត់ចែងបានដោយគ្មានការយល់ព្រមពីសហព័ទ្ធទាំងសងខាងបានឡើយ។[13]

ការបែងចែកទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែក គឺវាអាស្រ័យនឹងប្រព័ន្ធទ្រព្យសម្បត្តិ ដែលប្តីប្រពន្ធទាំងពីរជ្រើសរើស។ ក្រមរដ្ឋប្បវេណីខ្មែរទុកលទ្ធភាពឱ្យប្តីប្រពន្ធ ធ្វើកិច្ចសន្យាដើម្បីកំណត់ការបែងចែក និងការចាត់ចែងទ្រព្យសម្បត្តិ ដែលគេហៅថា ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា។ ក្រមរដ្ឋប្បវេណីតម្រូវថា កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធចាំបាច់ត្រូវតែធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ហើយដើម្បីអាចយកទៅតតាំងជាមួយនឹងតតិយជនបាន កិច្ចសន្យានេះត្រូវតែចុះបញ្ជីត្រឹមត្រូវនៅក្រសួងយុត្តិធម៌។ បើសិនជាប្តីប្រពន្ធមិនបានធ្វើកិច្ចសន្យាទ្រព្យសម្បត្តិទេ ការបែងចែក, ការគ្រប់គ្រង និងការចាត់ចែងទ្រព្យ គឺត្រូវធ្វើតាមច្បាប់ដែលបានកំណត់ ដែលគេហៅថា ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់។[14]

យោងតាមមាត្រា ៩៧២ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានចែងថា ទ្រព្យដោយឡែក គឺជាទ្រព្យសម្បត្តិដោយឡែក ដែលស្ថិតនៅក្រោមកម្មសិទ្ធិរបស់សហព័ទ្ធណាម្នាក់។ តាមមាត្រានេះ ទ្រព្យសម្បត្តិដោយឡែករួមមាន ៖ ទ្រព្យសម្បត្តិដែលមានមុនពេលរៀបអាពាហ៍ពិពាហ៍, ទ្រព្យសម្បត្តិដែលទទួលបានតាមរយៈប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងអាពាហ៍ពិពាហ៍ និងទ្រព្យសម្បត្តិដែលជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដោយឡែកផ្សេងទៀត នឹងត្រូវរាប់ជាទ្រព្យសម្បត្តិដោយឡែក។

[12] សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី ភាគ ៥ គន្ថីទី៧, ទំព័រទី៣៧។

[13] មាត្រា ៩៧៦ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[14] មាត្រា ៩៦៩ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

ទ្រព្យសម្បត្តិ ដែលសហព័ទ្ធមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍ មានន័យថាជាទ្រព្យដែលភាគីទាំងសងខាងមានមុនពេលរៀបការ ដោយទ្រព្យនោះ ត្រូវស្ថិតនៅជាកម្មសិទ្ធិដោយឡែករបស់ភាគីនោះដដែល មិនត្រូវរាប់ជាទ្រព្យរួមទេ។

ទ្រព្យសម្បត្តិដែលសហព័ទ្ធណាមួយទទួលបានក្នុងចំណងអាពាហ៍ពិពាហ៍ ប៉ុន្តែទទួលជាកេរមត៌ក ឬដោយអំណោយ (ប្រទានកម្ម ឬអច្ច័យទាន)។ ឧបមាថា ក្រោយរៀបការហើយ ឪពុកម្ដាយរបស់ភាគីខាងប្ដីគាត់ស្លាប់ទៅហើយបន្សល់ទុកទ្រព្យជាមត៌កទៅឱ្យកូន ទ្រព្យនេះត្រូវជាទ្រព្យផ្ទាល់របស់ប្ដី។ ក្នុងករណីអំណោយ បើម្ចាស់អំណោយឱ្យទៅអ្នកណា គឺជាទ្រព្យផ្ទាល់របស់អ្នកនោះ បើសិនជាម្ចាស់អំណោយបញ្ជាក់ច្បាស់ថាឱ្យទៅទាំងពីរនាក់ប្ដីប្រពន្ធ គឺជាទ្រព្យរួម។

ទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិទាំងពីរប្រភេទខាងលើ។ ឧទាហរណ៍ថាភាគីជាប្រពន្ធមានដីមួយកន្លែង ដែលជាទ្រព្យផ្ទាល់ ដែលគាត់មានតាំងពីមុនពេលរៀបការ។ ក្រោយមក ក្នុងពេលជាប់ចំណងអាពាហ៍ពិពាហ៍ គាត់លក់ដីនេះចេញ រួចហើយយកលុយដែលបានពីការលក់ដីនេះ ទៅទិញផ្ទះមួយល្វែង ផ្ទះនេះនៅតែជាទ្រព្យសម្បត្តិផ្ទាល់របស់គាត់ ទោះបីជាទិញនៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ក៏ដោយ។[15]

[15] សេង ឪណា, ការគ្រប់គ្រង ចាត់ចែង និងបែងចែកទ្រព្យសម្បត្តិប្ដីប្រពន្ធ, ១៣ ខែ ធ្នូ ឆ្នាំ ២០១២, គេហទំព័រ https://www.rfi.fr/km/marriage-and-property-ownership?fbclid=IwAR3QGlRNBX4GJd0ANPTlojt9nSzFkJKAh9V0qbiKxwj8sM8f2STCu33ceqY, ចូលទស្សនាថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២១។

# ជំពូកទី២

# សិទ្ធិ និងករណីយកិច្ចរបស់សហព័ទ្ធលើបំណុលរួម

តាមបញ្ញត្តិច្បាប់ជាធរមាន ក្រោយពេលរៀបអាពាហ៍ពិពាហ៍ សហព័ទ្ធទាំងសងខាងបានបង្កើតនូវទំនាក់ទំនងគតិយុត្តទាំងលើទ្រព្យ និងលើបំណុល។ ចំពោះសិទ្ធិ និងករណីយកិច្ចរបស់សហព័ទ្ធលើបំណុលរួម គឺមានលក្ខខណ្ឌក្នុងការអនុវត្តចំពោះករណីផ្សេងៗគ្នា ដែលក្នុងជំពូកនេះបានបែងចែកជា០៧ករណីរួមមាន ៖ ១. ករណីសហព័ទ្ធម្ខាងបាត់ខ្លួន, ២. ករណីបំបែកលំនៅសង្វាសដោយសហព័ទ្ធ ឬបំបែកលំនៅសង្វាសតាមអង្គហេតុ, ៣.ករណីសហព័ទ្ធក្លាយជាអសមត្ថជន, ៤. ករណីលែងលះរបស់សហព័ទ្ធ, ៥. ករណីសហព័ទ្ធជាពាណិជ្ជករ, ៦. ករណីសហព័ទ្ធជាជនបរទេស ៧. របបសន្តតិកម្ម។

## ១. ការបាត់ខ្លួនរបស់សហព័ទ្ធ

ក្នុងករណីដែលសហព័ទ្ធណាម្ខាង បានបាត់ខ្លួនទៅដោយគ្មានដំណឹងអស់រយៈពេលជាយូរ ដោយមិនដឹងថាសហព័ទ្ធនោះនៅរស់ ឬទទួលមរណភាព វាអាចធ្វើឱ្យប៉ះពាល់ទៅដល់ទំនាក់ទំនងគតិយុត្តរវាងបុគ្គលនោះ និងអាចបង្កជាផលលំបាកទៅដល់សហព័ទ្ធ និងតតិយជនផងដែរ។ ឧទាហរណ៍ សហព័ទ្ធម្ខាងទៀតមិនអាចរៀបអាពាហ៍ពិពាហ៍សារជាថ្មី (ទ្វេរពន្ធភាព) កាតព្វកិច្ចទទួលខុសត្រូវលើបំណុល និងការមិនអាចចាប់ផ្តើមបាននូវរបបសន្តតិកម្ម។ ហេតុនេះហើយ ក្នុងអំឡុងពេលចំណងអាពាហ៍ពិពាហ៍ បើសហព័ទ្ធណាម្ខាងបានបាត់ខ្លួនដោយពុំមានដំណឹងច្បាស់លាស់ក្នុងអំឡុងពេល ០៥ឆ្នាំ តុលាការអាចប្រកាសថាបុគ្គលនោះបានបាត់ខ្លួនតាមពាក្យសុំរបស់សហព័ទ្ធ។[16]

ម្យ៉ាងវិញទៀតក្នុងករណីដែលសហព័ទ្ធនោះបានបាត់ខ្លួនក្នុងលក្ខណៈពិសេសដូចជា សង្គ្រាម, ការលិចនាវា, រញ្ជួយដី, អគ្គីភ័យ និងស៊ូណាមិ ជាអាទិ៍ ដែលអាចជាមូលហេតុនៃមរណភាពរបស់សហព័ទ្ធដែលជួបប្រទះគ្រោះថ្នាក់ទាំងនោះ ហើយការមិនដឹងថារស់ ឬទទួលមរណភាពនោះ មានអំឡុងពេលយ៉ាងតិច ០១ឆ្នាំ ក្រោយពីគ្រោះថ្នាក់ទាំងនោះបានកន្លងផុតទៅ សហព័ទ្ធដែលនៅរស់អាចដាក់ពាក្យសុំទៅតុលាការ ដើម្បីឱ្យតុលាការប្រកាសអំពីការបាត់ខ្លួន។[17]

បុគ្គលដែលត្រូវបានតុលាការប្រកាសអំពីការបាត់ខ្លួនរួចហើយត្រូវចាត់ទុកថា បុគ្គលនោះបានទទួលមរណ-ភាព។[18] នេះគឺជាការ "ចាត់ទុក" ថាបានទទួលមរណភាព ហេតុនេះហើយ ទោះបីជារកឃើញភស្តុតាងផ្សេងទៀតក៏ដោយក៏មិនអាចលុបចោលនូវអានុភាពនៃការប្រកាសនេះបានដែរ លើកលែងតែមានចែងនៅក្នុងមាត្រា ៤៤ នៃក្រម

[16] មាត្រា ៤១ កថាខណ្ឌ ១ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[17] មាត្រា ៤១ កថាខណ្ឌ ២ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[18] មាត្រា ៤៣ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

រដ្ឋប្បវេណីឆ្នាំ២០០៧។ ការប្រកាសអំពីការបាត់ខ្លួនផ្តល់នូវអត្ថប្រយោជន៍ដល់សហព័ទ្ធដូចជារំលាយនូវចំណង អាពាហ៍ពិពាហ៍, ចាប់ផ្តើមនូវបេបសន្តតិកម្ម និងពាក់ព័ន្ធនឹងទំនាក់ទំនងគតិយុត្តផ្សេងៗដូចជាការបញ្ចប់ ឬបន្តនៃកិច្ចសន្យាខ្ចីប្រើប្រាស់ ឬកិច្ចសន្យាផ្សេងទៀតដែលបានធ្វើឡើងដោយជនដែលបានប្រកាសថាបានបាត់ខ្លួននោះ។[19] ប៉ុន្តែចំពោះបំណុលរួម សហព័ទ្ធដែលនៅរស់មានកាតព្វកិច្ចក្នុងការឆ្លើយតបទៅនឹងបំណុលទាំងនោះ ក្រោយពេលដែលបេបសន្តតិកម្មបានចាប់ផ្តើម ដែលចំណុចនេះនឹងត្រូវពណ៌នាលម្អិតនៅចំណុចបេបសន្តតិកម្ម។

អនុលោមតាមមាត្រា ៩៧៨ ចំណុច "គ" នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ក្នុងករណីដែលសហព័ទ្ធណាមួយបាត់ខ្លួនកន្លងហួសពីមួយឆ្នាំ គិតពីថ្ងៃដែលបាត់ខ្លួននោះមកដោយគ្មានដំណឹងអ្វីសោះ ហើយក៏គ្មាននរណាដឹងថាជននោះស្លាប់ ឬរស់ សហព័ទ្ធម្នាក់ទៀតអាចដាក់ពាក្យសុំលែងលះមកតុលាការ និងអាចរៀបអាពាហ៍ពាហ៍ថ្មីទៀតបាន បើផុតរយៈ ១៥ ថ្ងៃ គិតពីថ្ងៃប្រកាសសាលក្រមដែលបញ្ជាក់ថា ជននោះបានបាត់ខ្លួនពិតមែន។[20] ចំណុចខុសគ្នាចម្បងរវាងការរំលាយចំណងអាពាហ៍ពិពាហ៍ដោយការលែងលះ និងដោយសារការប្រកាសអំពីការបាត់ខ្លួន គឺការរំលាយចំណងអាពាហ៍ពិពាហ៍ដោយសារការប្រកាស់អំពីការបាត់ខ្លួន គឺពុំមានការបាត់បង់សិទ្ធិសន្តតិកម្មទេ ផ្ទុយទៅវិញការរំលាយចំណងអាពាហ៍ពិពាហ៍ដោយការលែងលះ គឺសហព័ទ្ធនឹងមិនអាចទទួលយកមត៌ករបស់សហព័ទ្ធថែមទាំងត្រូវទទួលខុសត្រូវចំពោះបំណុលដែលបានខ្ចីកន្លងមកផងដែរ។[21]

ក្រោយការប្រកាសអំពីការបាត់ខ្លួន ប្រសិនបើបញ្ជាក់ច្បាស់លាស់ថា បុគ្គលដែលបាត់ខ្លួននៅរស់ ឬបុគ្គលនោះ បានទទួលមរណភាណនៅពេលផ្សេងពីពេលដែលបានចាត់ទុកថាបានទទួលមរណភាពក្នុងការប្រកាសអំពីការបាត់ខ្លួននោះ តុលាការត្រូវលុបចោលនូវការប្រកាសអំពីការបាត់ខ្លួននោះ តាមការទាមទាររបស់សាមីខ្លួន ឬបុគ្គលដែលមានផលប្រយោជន៍។[22] ប្រសិនបើបានលុបចោលការប្រកាសនេះហើយ ជាគោលការណ៍ ត្រូវចាត់ទុកថា ពុំមានការប្រកាសអំពីការបាត់ខ្លួនតាំងពីដំបូងមក។ ដូច្នេះ សន្តតិកម្មដែលបានចាប់ផ្តើមហើយនោះ ក៏មិនត្រូវចាប់ផ្តើមដែរ។[23] ក៏ប៉ុន្តែចំពោះសហព័ទ្ធដែលបានទទួលទ្រព្យសម្បត្តិដោយអនុប្បទានពីសន្តតិជន ដោយផ្អែកលើការប្រកាសអំពីការបាត់ខ្លួននោះ ហើយត្រូវសហព័ទ្ធម្ខាងទៀតទាមទារទ្រព្យសម្បត្តិមកវិញ ដោយសារការលុបចោលនូវការប្រើប្រាស់អំពីការបាត់ខ្លួនពេលក្រោយនោះ សហព័ទ្ធដែលបានយកទ្រព្យទៅធ្វើការទូទាត់បំណុល ឬផ្គង់ផ្គង់តម្រូវការចាំបាច់សម្រាប់ទ្រទ្រង់ជីវភាពរស់នៅក្នុងគ្រួសារនាពេលកន្លងមកនោះអាចរងនូវការខូចខាត។[24] មាត្រា ៤៤ កថាខណ្ឌ ២ នៃក្រមរដ្ឋប្បវេណីបានបញ្ញត្តិថា បុគ្គលដែលមិនដឹងថា ការប្រកាសបាត់ខ្លួននោះផ្ទុយពីការពិត នៅ

[19] សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី គន្ថីទី១ ដល់គន្ថីទី៣, ទំព័រទី៣៥ ដល់ទី៣៦។
[20] ច្បាប់ចាស់ដែលនិរាករណ៍បានចែងដូចគ្នាក្នុងមាត្រា ១០ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩។
[21] សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី គន្ថីទី១ ដល់គន្ថីទី៣, ទំព័រទី៣៥ ដល់ទី៣៦។
[22] មាត្រា ៤៤ កថាខណ្ឌ ១ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
[23] សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី គន្ថីទី១ ដល់គន្ថីទី៣, ទំព័រទី៣៧។
[24] សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី គន្ថីទី១ ដល់គន្ថីទី៣, ទំព័រទី៣៧។

ពេលដែលខ្លួនបានទទួលទ្រព្យសម្បត្តិនោះ ត្រូវមានករណីយកិច្ចសងត្រឹមតែកម្រិតនៃផលប្រយោជន៍ដែលខ្លួននៅតែទទួលផលប្រយោជន៍តែប៉ុណ្ណោះ។ សហព័ទ្ធដែលបានប្រើប្រាស់ទ្រព្យសម្បត្តិដែលបានមកដោយសន្តតិកម្មនោះ ប្រសិនបើទាមទារឱ្យសហព័ទ្ធនោះសងទាំងភាគដែលខ្លួនបានប្រើប្រាស់អស់ទៅហើយនោះ គឺអាចមានបញ្ហាធ្ងន់ធ្ងរចំពោះបុគ្គលនោះ។ ដូច្នេះហើយទើបមានបញ្ញត្តិសម្រាប់សង្គ្រោះបុគ្គលដែលបានធ្វើលទ្ធកម្មផ្ទាល់ដោយសុចរិតដោយគ្រាន់តែសងត្រឹមតែភាគដែលសល់នោះបានហើយ តែក្នុងករណីដែលបានប្រើប្រាស់ទ្រព្យសម្បត្តិដែលបានទទួលនោះអស់ហើយ សម្រាប់ទ្រទ្រង់ជីវភាព ឬទូទាត់បំណុលរួមនោះ មិនចាំបាច់សងវិញទេ។[25]

អានុភាពនៃសកម្មភាពដែលបានធ្វើឡើង ដោយទុកចិត្តលើការប្រកាសអំពីការបាត់ខ្លួន នៅក្រោយការប្រកាសអំពីការបាត់ខ្លួន ប៉ុន្តែមុនពេលលុបចោលការប្រកាសអំពីការបាត់ខ្លួននោះ ពុំទទួលឥទ្ធិពល ដោយសារការលុបចោលការប្រកាសអំពីការបាត់ខ្លួនឡើយ។[26] ក្នុងករណីក្រោយពេលតុលាការបានប្រកាសអំពីការបាត់ខ្លួនរបស់សហព័ទ្ធម្ខាង សហព័ទ្ធនៅរស់ដែលគាត់ជាស្ត្រីមេផ្ទះ និងត្រូវមើលថែបីបាច់ចិញ្ចឹមកូនក្នុងបន្ទុក ព្រមទាំងមានកាតព្វកិច្ចឆ្លើយតបទៅនឹងបំណុលរួមដែលសហព័ទ្ធទាំងសងខាងជំពាក់ពីមុនមក គាត់បានសម្រេចចិត្តលក់ដីមួយកន្លែងដែលជាទ្រព្យរួមទៅឱ្យតតិយជន។ ការទិញ-លក់នេះធ្វើឡើងក្រោយពេលដែលតុលាការបានប្រកាសអំពីការបាត់ខ្លួនរបស់បុរសដែលជាប្តី ហើយតតិយជននោះ គឺជាតតិយជនសុចរិត។ ទោះបីជាក្រោយមកបុរសដែលជាប្តីបានត្រឡប់មកវិញ រួចបានស្នើសុំឱ្យតុលាការលុបការប្រកាសអំពីការបាត់ខ្លួន ហើយតុលាការបានឯកភាពតាមការស្នើសុំក៏ដោយ គឺមិនអាចប្តឹងមោឃភាពកិច្ចសន្យាទិញ-លក់ដី និងទាមទារដីត្រឡប់មកវិញបានឡើយ ព្រោះតតិយជនដែលបានទិញដីពីសន្តតិជន គឺជាតតិយជនសុចរិតមិនបានដឹងថាការប្រកាសអំពីការបាត់ខ្លួននោះខុសនឹងការពិត ដូច្នេះអ្នកទិញពុំមានកាតព្វកិច្ចសងដីនោះទៅបុគ្គលដែលបាត់ខ្លួននោះវិញទេ។

## ២. ការបំបែកលំនៅសន្ធាសតាមអង្គហេតុ

អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឱឡារិកមួយ ធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ដែលប្តេជ្ញាថា ខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន។[27] ដោយសារទំនាក់ទំនងស្របច្បាប់ ធ្វើឱ្យបុរស និងស្ត្រីនេះចាកផុតពីការចោទប្រកាន់ក្នុងបទរំលោភសេពសន្ថវៈ លើកលែងមានកំណត់នៅក្នុងច្បាប់ផ្សេង។ ទំនាក់ទំនងរវាងប្តី និងប្រពន្ធ គឺជាទំនាក់ទំនងក្រៅបេតិកភណ្ឌ ដែលប្តីប្រពន្ធត្រូវរួមរស់ជីវភាពជាមួយគ្នា ហើយត្រូវសហការ សង្គ្រោះគ្នាទៅវិញទៅមក។ ប្តីប្រពន្ធមានករណីយកិច្ចស្រឡាញ់គ្នាទៅវិញទៅមក គោរពគ្នាទៅវិញទៅមក ថែរក្សាគ្នា និងជួយគ្នាទៅវិញទៅមក ដើម្បីឈានទៅកាន់វឌ្ឍនភាពព្រមទាំង

---

[25] សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី គន្ថីទី១ ដល់គន្ថីទី៣, ទំព័រទី៣៧ ដល់ទំព័រទី៣៨។

[26] មាត្រា ៤៨ កថាខណ្ឌ ៣ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[27] មាត្រា ៣ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ក្រ, ១៧ កក្កដា ១៩៨៩ (ចាប់ពីពេលនេះហៅថា ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ)

កសាងគ្រួសារមួយមានសាមគ្គីភាព និងប្រកបដោយសុភមង្គល។[28] ដូច្នេះទោះក្នុងកាលៈទេសៈបែបណាក៏ដោយ ក៏ប្តីប្រពន្ធមិនអាចបោះបង់គ្នា ឬចាកចេញដោយគ្មានមូលហេតុ ដោយបន្សល់ទុកនូវបន្ទុកគ្រួសារដ៏ធ្ងន់ធ្ងរ និង បំណុលផ្សេងៗជាច្រើនទៀតដែលបានខ្ចីក្នុងអំឡុងពេលនៃចំណងអាពាហ៍ពាហ៍ ឱ្យសហព័ទ្ធម្ខាងទៀតជាអ្នក រ៉ាប់រងតែម្នាក់ឯងនោះទេ ព្រោះវាផ្ទុយទៅនឹងគោលការណ៍ច្បាប់ និងគោលបំណងនៃអាពាហ៍ពិពាហ៍។

**ឧទាហរណ៍ ៖** ក្រោយពីរៀបអាពាហ៍ពិពាហ៍២ឆ្នាំក្រោយមក លោកស្រី **ខ** បានបង្កើតបានកូនប្រុសម្នាក់។ ក្រោយពីរៀបអាពាហ៍ពិពាហ៍ ៤ ឆ្នាំ ប្រាក់សន្សំរបស់ លោក **ក** និងលោកស្រី **ខ** មានចំនួន ២២.០០០ ដុល្លារ។ អ្នក ទាំងពីរបានគិតថានឹងទិញផ្ទះល្វែងមួយកន្លែងនៅក្នុងរាជធានីភ្នំពេញ ហើយអ្នកទាំងពីរក៏បានរកបានផ្ទះមួយកន្លែង ដែលមានតម្លៃ ៦០.០០០ ដុល្លារ។ ដូច្នេះអ្នកទាំងពីរក៏បានសម្រេចចិត្តខ្ចីលុយពីធនាគារចំនួន ៤០.០០០ ដុល្លារ បង់ទៅឱ្យអ្នកលក់ ហើយបានទិញយកផ្ទះនោះ។ អ្នកទាំងពីរបានធ្វើកិច្ចសន្យាឥណទានជាមួយនឹងធនាគារ។ កិច្ចសន្យាឥណទាននោះមានខ្លឹមសារថានឹងសងប្រាក់កម្ចីទាំងអស់ចំនួន ៤០.០០០ ដុល្លារ ដោយធ្វើការសងចំនួន ៤០០ ដុល្លារ ជារៀងរាល់ខែ រយៈពេល ១០០ខែ ស្មើនឹង៨ឆ្នាំ៤ខែ។ លោក **ក** និងលោកស្រី **ខ** បានចុះហត្ថលេខា ទាំងពីរនាក់ក្នុងនាមជាកូនបំណុលលើកិច្ចសន្យាឥណទាននោះ។ អ្នកទាំងពីរបានចុះបញ្ជីផ្ទះនោះដោយដាក់ឈ្មោះ រួមថា លោក **ក** និងលោកស្រី **ខ** ចំពោះដី និងផ្ទះថ្មីនោះ។ កូនរបស់លោក **ក** និងលោកស្រី **ខ** មានជម្ងឺបេះដូងតាំង ពីកំណើត ហើយដើម្បីព្យាបាលជម្ងឺនេះចាំបាច់ត្រូវតែទទួលការវះកាត់។ ដើម្បីព្យាបាលចាំបាច់ត្រូវចំណាយប្រាក់ សរុបចំនួន ១០.០០០ ដុល្លារ។ ដូច្នេះ លោក **ក** បានខ្ចីលុយពីមិត្តភក្តិចំនួន ១០.០០០ ដុល្លារ។ លោក **ក** និងលោក ស្រី **ខ** បានយកកូនទៅធ្វើការវះកាត់ ហើយជម្ងឺរបស់កូនអ្នកទាំងពីរក៏បានជាសះស្បើយ។ ក្រោយមកលោក **ក** ក៏ មានទំនាក់ទំនងស្នេហាលួចលាក់ជាមួយនឹងស្រីនៅខាងក្រៅដោយមិនអោយលោកស្រី **ខ** ដឹង។ មួយឆ្នាំក្រោយមក លោក **ក** ក៏បានចាកចេញពីផ្ទះរួចទៅរស់នៅជាមួយនឹងស្រីកំណាន់ ដោយបានផ្លាស់ប្តូរលេខទូរស័ព្ទថ្មី និងឈប់ធ្វើ ការទំនាក់ទំនងមកប្រពន្ធ ថែមទាំងមិនបានផ្តល់ប្រាក់សម្រាប់ផ្គត់ផ្គង់ជីវភាពទៀតផង។ លោកស្រី **ខ** ចាំបាច់ត្រូវ បង់ប្រាក់ ៤០០ ដុល្លារ នៃប្រាក់ឥណទានជារៀងរាល់ខែដោយម្នាក់ឯង និងថ្លៃចំណាយផ្សេងៗនៅក្នុងផ្ទះសរុប ប្រហែល ៣០០ ដុល្លារជារៀងរាល់ខែ។ ដូច្នេះ លោកស្រី **ខ** គិតថានឹងលក់ផ្ទះនោះទៅឱ្យតតិយជនដើម្បីដោះស្រាយ បំណុល រួចរើទៅនៅផ្ទះជោកៗ។ ខណៈនោះអ្នកដែលស្គាល់គ្នាបាននិយាយមកកាន់ លោកស្រី **ខ** ថាចង់ទិញផ្ទះ នោះក្នុងតម្លៃ ៤៥.០០០ ដុល្លារ ហើយលោកស្រី **ខ** គិតថាចង់លក់ផ្ទះនោះក្នុងតម្លៃនេះឱ្យទៅអ្នកនោះ។ នៅពេល នោះតើលោកស្រី **ខ** អាចលក់ផ្ទះនោះទៅឱ្យអ្នកស្គាល់គ្នាបានដែរឬទេ ដើម្បីយកប្រាក់មកដោះស្រាយបំណុល?

អនុលោមតាមមាត្រា ៩៧៦ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បើគ្មានការយល់ព្រមពីប្តីប្រពន្ធទាំង សងខាងទេ ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធមិនអាចយកទៅលក់ ឬធ្វើការចាត់ចែងផ្សេងទៀតបានឡើយ។ ប៉ុន្តែក្នុង ករណីសិក្សាខាងលើនេះ លោកស្រី **ខ** បានព្យាយាមធ្វើការទាក់ទងទៅ លោក **ក** ជាច្រើនលើកច្រើនសារ ប៉ុន្តែ លោក **ក**

[28] មាត្រា ៩៦៦ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

គ្មានការឆ្លើយតបនោះទេ ហើយនៅតែបន្តគ្មានដំណឹង។ ដំណោះស្រាយដែលលោកស្រី **ខ** អាចលក់ផ្ទះដើម្បីយកប្រាក់ទៅដោះស្រាយបំណុល និងផ្គត់ផ្គង់ជីវភាពបន្ត គឺដាក់ពាក្យបណ្តឹងទៅតុលាការដែលមានសមត្ថកិច្ចដើម្បីទទួលការអនុញ្ញាតក្នុងការលក់ ឬធ្វើការចាត់ចែងផ្សេងទៀតនូវទ្រព្យសម្បត្តិរួម ដោយសម្អាងហេតុថាស្ថានភាពមិនអាចជៀសវាងបាន សម្រាប់រក្សាជីវភាពរស់នៅ ដោយត្រូវសងប្រាក់ឥណទានទៅធនាគារក្នុងមួយខែ ៤០០ ដុល្លារ និងប្រាក់ជំពាក់ដែល លោក **ក** ខ្ចីពីមិត្តភក្តិចំនួន ១០.០០០ ដុល្លារ កន្លងមក ទោះបីជាបំណុលនេះពុំបានធ្វើជាលិខិតលាយល័ក្ខណ៍អក្សរ ប៉ុន្តែវាជាសោហ៊ុយដើម្បីព្យាបាលជម្ងឺរបស់កូន ដូចនេះវាជាបំណុលរួម ដែលលោកស្រី **ខ** ត្រូវសងទៅមិត្តភក្តិ លោក **ក** ក្រោយពីលក់ផ្ទះបាន។

## ៣. សហព័ទ្ធជាអសមត្ថជន

នៅអំឡុងពេលរៀបអាពាហ៍ពិពាហ៍ នៅពេលដែលសហព័ទ្ធណាម្ខាងបានជាប់នូវបំណុលដែលខ្ចីពីម្ចាស់បំណុលរួចមិនទាន់បានសងនូវបំណុលនោះ ដោយក្រោយមកបានរងនូវផ្នែកបញ្ញាស្មារតីក្នុងការវិនិច្ឆ័យដោយឧបទ្ទវហេតុណាមួយដែលមិនបានដឹងមុន ដែលធ្វើឱ្យសហព័ទ្ធដែលជាប់នូវបំណុលនោះត្រូវដាក់ឱ្យស្ថិតក្រោមអាណាព្យាបាលទូទៅ ឬហិតូបត្ថម្ភ។ នៅក្នុងហេតុការនេះ ក្នុងការទូទាត់នូវបំណុលរបស់សហព័ទ្ធដែលស្ថិតក្រោមអាណាព្យបាលទូទៅ ឬហិតូបត្ថម្ភ ត្រូវធ្វើឡើង ឬទូទាត់ ដោយការទទួលបានការអនុញ្ញាតពីតុលាការក្នុងការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ។[29] របបអាណាព្យាបាលទូទៅ ឬហិតូបត្ថម្ភ គឺសម្តៅទៅលើជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាព ឬមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដែលមានវិបត្តិផ្នែកបញ្ញាស្មារតី។[30] ក្នុងការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិសហព័ទ្ធមានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់, ទទួលផលប្រយោជន៍ និងគ្រប់គ្រងទ្រព្យសម្បត្តិរួម ដែលជាទ្រព្យទាំងឡាយណា ដែលប្តីប្រពន្ធទាំងសងខាង ឬតែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។[31] មិនតែប៉ុណ្ណោះ សហព័ទ្ធមានសិទ្ធិក្នុងការគ្រប់គ្រង និងប្រើប្រាស់នៅក្នុងទំហំដែលចាំបាច់ដោយផ្អែកលើការចាំបាច់នៅក្នុងជីវភាពរបស់ខ្លួន។[32]

**ឧទាហរណ៍ ៖** នៅអំឡុងពេលរៀបអាពាហ៍ពិពាហ៍ លោក **ក** បានទៅខ្ចីបំណុលពីម្ចាស់បំណុលម្នាក់ដោយក្នុងគោលបំណង យកប្រាក់ដែលបានខ្ចីនោះទៅដោះស្រាយក្នុងជីវភាពគ្រួសាររបស់លោក។ បន្ទាប់មកមិនបានប៉ុន្មាន លោក **ក** បានជួបឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍ដោយចៃដន្យ។ ការជួបឧបទ្ទវហេតុនេះធ្វើឱ្យ លោក **ក** បាត់បង់ស្មារតីដោយប៉ះទង្គិចយ៉ាន់ធ្ងន់ធ្ងរត្រង់ផ្នែកក្បាលដែលបណ្តាលឱ្យលោក **ក** ត្រូវស្ថិតក្នុងសភាពជានិរន្តរ៍ដែលខ្វះសមត្ថភាព ឬមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និងវិនិច្ឆ័យ ដែលលោក **ក** ត្រូវស្ថិតក្រោម

[29] មាត្រា ៩៧៦ កថាខណ្ឌ ២ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[30] មាត្រា ២៤ កថាខណ្ឌ ២ និងមាត្រា ២៨ កថាខណ្ឌ ១ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[31] មាត្រា ៩៧៣ និង មាត្រា ៩៧៤ កថាខណ្ឌ ១ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[32] មាត្រា ៩៧៤ កថាខណ្ឌ ២ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

អាណាព្យាបាលទូទៅ ឬហិតូបត្ថម្ភ។ ក្រោយពីរងនូវការប៉ះពាល់យ៉ាងធ្ងន់ធ្ងរនេះរួច ម្ចាស់បំណុលដែល លោក **ក** បានខ្ចីនៅអំឡុងពេលរៀបអាពាហ៍ពិពាហ៍បានមកទារនូវបំណុលនោះ ដែលលោក **ក** ជំពាក់។

ក្នុងករណីសិក្សានេះ លោកស្រី **ខ** ដែលជាប្រពន្ធរបស់ លោក **ក** គឺមានសិទ្ធិក្នុងការចាត់ចែងទៅលើទ្រព្យសម្បត្តិរួម ដែលជាទ្រព្យសម្បត្តិដែលរកបានក្រោយអាពាហ៍ពិពាហ៍របស់លោក **ក** និង លោកស្រី **ខ** ដែលត្រូវយកទៅទូទាត់ក្នុងការសងជំនួសប្តី ដែលប្តីរបស់ខ្លួនត្រូវស្ថិតក្រោមអាណាព្យាបាលទូទៅ ឬហិតូបត្ថម្ភ ទៅឱ្យម្ចាស់បំណុល ដោយលោកស្រី **ខ** ត្រូវទទួលខុសត្រូវចំពោះកាតព្វកិច្ចក្នុងការសងនូវបំណុលរបស់ប្តីដែលបន្សល់ទុកមកនោះ។ ក្នុងករណីសិក្សានេះ បើសិនស្ថានភាពមិនអាចជៀសវាងបាន សម្រាប់ការថែទាំជីវភាពរួមក្នុងអាពាហ៍ពិពាហ៍ និងដើម្បីរក្សាជីវភាពរស់នៅ នោះលោកស្រី **ខ** អាចលក់ ឬធ្វើការចាត់ចែងផ្សេងទៀត នូវទ្រព្យសម្បត្តិរួមបាន ដោយត្រូវទទួលការអនុញ្ញាតពីតុលាការ។[33]

## ៤. ការលែងលះ

ការរៀបអាពាហ៍ពិពាហ៍ គឺជាការស្ម័គ្រចិត្ត ដែលបុរស និងស្ត្រីមានសិទ្ធិពេញលេញក្នុងការជ្រើសរើសគូស្រករបស់ខ្លួនបាន តែបើក្រោយពេលរស់នៅជាមួយគ្នាឃើញថាមានសហព័ទ្ធម្នាក់ត្រូវសហព័ទ្ធម្ខាងទៀតរំលោភបំពានធ្ងន់ធ្ងរ ឬក៏សហព័ទ្ធទាំងសងខាងយល់ថា ពុំអាចរស់ចុះសម្រុងនឹងគ្នាតទៅទៀតបាន[34] ដោយប្រការណាមួយដ៏សមស្រប និងគ្រប់គ្រាន់ដែលអាចបញ្ជាក់បានថាខ្លួនពុំអាចរស់នៅជាមួយគ្នាទៀតបាននោះ សហព័ទ្ធទាំងពីរអាចធ្វើការប្តឹងទៅតុលាការក្នុងការផ្តាច់ចំណងអាពាហ៍ពិពាហ៍របស់ភាគីទាំងសងខាងបាន ពោលគឺតម្រូវឱ្យគូភាគីសុខចិត្តព្រមព្រៀង ដោយគ្មានការបង្ខិតបង្ខំ តុលាការនឹងកាត់សេចក្តីទៅតាមការព្រមព្រៀងនោះជានិច្ច។ បន្ទាប់ពីការផ្តាច់ចំណងអាពាហ៍ពិពាហ៍ ឬការលែងលះរបស់សហព័ទ្ធហើយនោះ គឺត្រូវបែងចែកទ្រព្យសម្បត្តិដោយយុត្តិធម៌ផ្អែកតាមការពិភាក្សារបស់ភាគីទាំងសងខាង។[35]

ការលែងលះដែលផ្តាច់ចំណងអាពាហ៍ពិពាហ៍រវាងប្តីប្រពន្ធ គឺត្រូវបានធ្វើនៅក្នុងនីតិវិធីក្នុងការលែងលះសម្រាប់ចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ មាន០២ប្រភេទ ដែលជា ការលែងលះដោយការព្រមព្រៀង និងការលែងលះដែលមានមូលហេតុដូចមានចែងនៅក្នុងក្រមរដ្ឋប្បវេណី គឺជាការលែងលះដោយមិនមានការព្រមព្រៀង។

ការលែងលះដោយមានការព្រមព្រៀង មានន័យថាប្តី និងប្រពន្ធ បានឯកភាពគ្នាដោយស្ម័គ្រចិត្តរំលាយចំណងអាពាហ៍ពិពាហ៍ ហើយភាគីទាំងសងខាងត្រូវដាក់ពាក្យសុំលែងលះ ដោយភ្ជាប់ជាមួយកិច្ចព្រមព្រៀងលែងលះដោយស្ម័គ្រចិត្ត ទៅសាលាដំបូងរាជធានី/ខេត្ត។ បើតុលាការរកឃើញថាភាគីទាំងពីរមានឆន្ទៈព្រមព្រៀងពិត

[33] មាត្រា ៩៧៦ កថាខណ្ឌ ២ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[34] មាត្រា ៣៩ ច្បាប់ស្តីអាពាហ៍ពិពាហ៍ និងគ្រួសារ។

[35] មាត្រា ៩៨០ កថាខណ្ឌ ១ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

ប្រាកដ[36] ក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍នោះ តុលាការនឹងសម្រេចឱ្យភាគីលែងលះគ្នាតាមរយៈអំណាច "ដីកាសម្រេច"[37] ។

ការលែងលះដែលមានមូលហេតុដូចមានចែងនៅក្នុងក្រមរដ្ឋប្បវេណី គឺជាការលែងលះដោយមិនមានការព្រមព្រៀង មានន័យថាប្តីប្រពន្ធ មិនមានឆន្ទៈក្នុងការលែងលះ តែភាគីម្ខាងទៀតមិនអាចរួមរស់ជាមួយគ្នាទៀតបាន ដោយយោងទៅលើមូលហេតុនៃការលែងលះ ដែលមានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីដូចខាងក្រោម[38]៖

- មានអំពើផិតក្បត់ ទៅលើសហព័ទ្ធ
- បោះបង់សហព័ទ្ធចោល ដោយគ្មានមូលហេតុត្រឹមត្រូវ
- មិនដឹងច្បាស់ថា សហព័ទ្ធស្លាប់ ឬរស់អស់រយៈពេលជាង១ឆ្នាំ
- សហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ អស់រយៈពេលជាង ០១ឆ្នាំ ដែលផ្ទុយនឹងគោលបំណងអាពាហ៍ពិពាហ៍
- ករណីផ្សេងទៀតដែលនាំឱ្យទំនាក់ទំនងត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន ។

ដូច្នេះភាគីប្តី ឬប្រពន្ធ អាចដាក់ពាក្យបណ្តឹងទាមទារលែងលះគ្នា ទៅសាលាដំបូងរាជធានី/ខេត្ត ហើយបើតុលាការរកឃើញថាមានមូលហេតុ និងភស្តុតាងបញ្ជាក់យ៉ាងច្បាស់លាស់ថាភាគីទាំងពីរពិតជាមិនអាចរួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធទៀតបាន នោះតុលាការត្រូវសម្រេចឱ្យភាគីលែងលះគ្នាតាមរយៈអំណាច "សាលក្រម" នេះបើយោងតាមច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។ បើទោះបីជាពាក្យបណ្តឹងទាមទារការលែងលះរបស់ភាគីមានមូលហេតុដូចមានរៀបរាប់ខាងលើក៏ដោយ ប៉ុន្តែប្រសិនបើតុលាការយល់ឃើញថាការលែងលះនោះបណ្តាលឱ្យការទ្រទ្រង់ជីវភាពរបស់ប្តីប្រពន្ធ ឬកូន ក្រលំបាក ឬឈឺចាប់ដែលពុំអាចទ្រាំទ្របាន ឬដោយសារតែការទាមទារនោះផ្ទុយនឹងភាពសុចរិតនោះ តុលាការអាចច្រានចោលការទាមទារលែងលះគ្នានោះបាន ដោយពិចារណាលើស្ថានភាពជាក់ស្តែង ឬដោយឆន្ទានុសិទ្ធិ។[39]

ជាចុងក្រោយការលែងលះ ឬការរំលាយចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ ដែលប្តីប្រពន្ធបានចុះសំបុត្រអាពាហ៍ពិពាហ៍ ត្រូវតែធ្វើឡើងតាមផ្លូវតុលាការ ។ ភាគី(ប្តី/ប្រពន្ធ) មិនអាចបង្កើតកិច្ចព្រមព្រៀងលែងលះក្រៅប្រព័ន្ធតុលាការ ឬគ្រាន់តែដាក់លិខិតជូនដំណឹងទៅសាលាឃុំ/សង្កាត់បានទេ។ ប្រសិនបើមិនបានឆ្លងកាត់ការសម្រេចសេចក្តីតាមរយៈសេចក្តីសម្រេចរបស់តុលាការនោះទេ ចំណងអាពាហ៍ពិពាហ៍របស់ពួកគេត្រូវទុកជាបានការដដែល។ ផ្ទុយមកវិញបើសិនជាចំណងអាពាហ៍ពិពាហ៍ដែលបុរស-នារី បានរួមរស់នៅជាមួយគ្នាដោយគ្រាន់តែរៀបការតាម

[36] មាត្រា ៩៧៩ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[37] មាត្រា ៣ កថាខណ្ឌ ២ ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។

[38] មាត្រា ៩៧៨ កថាខណ្ឌ ១ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[39] មាត្រា ៩៧៨ កថាខណ្ឌ ៣ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

បែបប្រពៃណីទំនៀមទម្លាប់ ឬពិធីតាមបែបសាសនា ដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ (អនីតិសង្វាស) ពួកគេពុំចាំបាច់ឆ្លងកាត់ការលែងលះ ឬការរំលាយចំណងអាពាហ៍ពិពាហ៍ តាមរយៈប្រព័ន្ធតុលាការបានឡើយ ពោលគឺបុរស-នារីរូបនោះ គ្រាន់តែរស់នៅបែកគ្នាជាការស្រេច ប៉ុន្តែក្នុងករណីពួកគេមានកូនៗ ឬទ្រព្យសម្បត្តិ ដែលត្រូវធ្វើការបែងចែកអំណាចមេបា និងការផ្តល់អាហារកាតព្វកិច្ច ឬការបែងចែកទ្រព្យដោយឡែក/ទ្រព្យរួម ពួកគេអាចដាក់ពាក្យសុំ ឬពាក្យបណ្តឹងទៅតុលាការដើម្បីសម្រេចសេចក្តីជូនពួកគេបាន (ពាក្យបណ្តឹងដែលមានកម្មវត្ថុស្នើសុំសិទ្ធិអំណាចមេបាលើកូន ឬ/និង បែងចែកទ្រព្យ)។[40]

នៅក្នុងការលែងលះនេះដែរ ទាក់ទងទៅលើបំណុល និងកាតព្វកិច្ចទាំងឡាយ របស់សហព័ទ្ធនៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ដោយត្រូវធ្លាក់បន្ទុកទ្រព្យសម្បត្តិរួម ដោយបំណុល និងកាតព្វកិច្ចទាំងឡាយ ដែលសហព័ទ្ធទាំងពីរបានព្រមព្រៀងគ្នាសម្រេច ក្នុងពេលអាពាហ៍ពិពាហ៍ ឬដែលសហព័ទ្ធណាម្នាក់សម្រេចក្នុងរយៈពេលមានចំណង អាពាហ៍ពិពាហ៍ដោយមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត។[41] ក្នុងន័យនេះ ការដែលជាប់នូវបំណុល ឬកាតព្វកិច្ចទាំងឡាយ របស់សហព័ទ្ធទាំងពីរដែលស្ថិតក្នុងអំឡុងអាពាហ៍ពិពាហ៍ នោះអាចយកទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធដែលរកបានក្នុងពេលអាពាហ៍ពិពាហ៍ មកដោះស្រាយទៅលើបំណុល ឬកាតព្វកិច្ចណាមួយដែលសហព័ទ្ធបានព្រមព្រៀងជាមួយគ្នា។

គួរបញ្ជាក់ថា ទ្រព្យសម្បត្តិប្តីប្រពន្ធអាចមានទ្រព្យរួម និងទ្រព្យដោយឡែក ចំណែកកាតព្វកិច្ចលើបំណុលវិញ ក៏ត្រូវមានការបែងចែកជាបំណុលរួម និងបំណុលដោយឡែកដែរ។

បំណុលរួម ដែលប្តីប្រពន្ធត្រូវតែទទួលខុសត្រូវរួមគ្នា គឺបំណុលទាំងឡាយណា ដែលប្តីប្រពន្ធទាំងពីរជាអ្នកខ្ចីរួមគ្នា ឬក៏សហព័ទ្ធណាមួយជាអ្នកខ្ចី ប៉ុន្តែមានការព្រមព្រៀងជាលាយល័ក្ខណ៍អក្សរពីសហព័ទ្ធម្ខាងទៀត។ មានប្រភេទបំណុលខ្លះ គឺមានបំណុល ដែលមានជាប់ពាក់ព័ន្ធនឹងការរក្សាជីវភាពរួមប្តីប្រពន្ធ ការអប់រំ ថែទាំ និងព្យាបាលកូន បំណុលដែលជាប់ពាក់ព័ន្ធនឹងការគ្រប់គ្រង និងថែរក្សាទ្រព្យសម្បត្តិរួម ត្រូវបានច្បាប់ចាត់ទុកថាជាបំណុលរួមដោយស្វ័យប្រវត្តិ ដែលប្តីប្រពន្ធចាំបាច់ត្រូវតែទទួលខុសត្រូវរួមគ្នា ទោះបីសហព័ទ្ធណាជាអ្នកខ្ចីក៏ដោយ ហើយគ្មានការព្រមព្រៀងជាលាយល័ក្ខណ៍អក្សរពីសហព័ទ្ធម្ខាងទៀតក៏ដោយ។

**ឧទាហរណ៍ ៖** នៅក្នុងពេលរួមរស់ជាមួយគ្នាជាប្តីប្រពន្ធ លោក **ក** និងលោកស្រី **ខ** បានព្រមព្រៀងគ្នាក្នុងការខ្ចីលុយពីធនាគារមួយ ក្នុងគោលបំណងយកលុយទាំងនោះទៅបង់រំលោះផ្ទះមួយកន្លែង។ បន្ទាប់ក្រោយមកគ្រួសាររបស់លោក **ក** និងលោកស្រី **ខ** បានឈានទៅដល់ការលែងលះគ្នាដោយមូលហេតុដោយសារការរស់នៅមិនចុះសម្រុងនឹងគ្នា និងមានការរកាំរកុះជាមួយគ្នាជាញឹកញាប់ ទើបធ្វើឱ្យអ្នកទាំងពីរដាក់ពាក្យប្តឹងទៅតុលាការដើម្បីធ្វើការលែងលះគ្នា។ ការលែងលះនេះបន្សល់ទុកនូវបំណុល និងកាតព្វកិច្ចដែលប្តីប្រពន្ធអ្នកទាំងពីរបានខ្ចីពីធនាគារពី

[40] មាត្រា ៩៨៣ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[41] មាត្រា ៣៥ កថាខណ្ឌ ២ ច្បាប់ស្តីអាពាហ៍ពិពាហ៍ និងគ្រួសារ។

មុនមក ដែលធ្វើឱ្យមានការបែងចែក ដោយត្រូវយកទ្រព្យសម្បត្តិរួម ដែលកើតឡើងពីការរកបានរបស់សហព័ទ្ធទាំងសងខាងក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ មកដោះស្រាយទៅលើបញ្ហាបំណុលនោះ។

## ៥. សហព័ទ្ធជាពាណិជ្ជករ

ក្រោយពេលរៀបអាពាហ៍ពិពាហ៍ សហព័ទ្ធចាំបាច់ត្រូវតែមានការងារ ឬមុខរបរមួយជាក់លាក់ដើម្បីអាចទ្រទ្រង់ជីវភាពគ្រួសារទៅថ្ងៃមុខបាន និងបង្កើតសុភមង្គលនៅក្នុងក្រុមគ្រួសារមួយផងដែរ។ ជាទូទៅយើងសង្កេតឃើញថានៅក្នុងសង្គមខ្មែរពីសម័យមុនមក គេចាត់ទុកបុរសគឺជាមេគ្រួសារ ដែលមានតួនាទីរកប្រាក់ដើម្បីយកមកផ្គត់ផ្គង់គ្រួសារទាំងមូល ចំណែកឯស្ត្រី គឺជាមេផ្ទះដែលមានតួនាទីមើលថែរក្សាកូនចៅ, ចាត់ចែងការងារក្នុងផ្ទះ និងទុកដាក់រាល់ទ្រព្យសម្បត្តិដែលប្តីរកបាន។ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញបានបញ្ញត្តិថា ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់។ ប្រជាពលរដ្ឋខ្មែរសម្តៅលើប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ពោលគឺបុរស និងស្ត្រី គឺមានសិទ្ធិស្មើគ្នា។ រហូតមកដល់បច្ចុប្បន្ន គឺមានការប្រែប្រួលយ៉ាងខ្លាំង ដោយស្ត្រីទទួលបានការអប់រំទូលំទូលាយជាងពេលកន្លងមក ហើយស្ត្រីអាចក្លាយជាមេគ្រួសារ ដែលអាចគ្រប់គ្រងគ្រួសារបានយ៉ាងល្អមិនចាញ់បុរសផងដែរ។ ប្តីប្រពន្ធ គឺមានសិទ្ធិស្មើគ្នាក្នុងការប្រកបវិជ្ជាជីវៈផ្ទាល់ខ្លួន ហើយក្នុងអត្ថបទនេះយើងនឹងសិក្សាលម្អិតពីករណីដែលសហព័ទ្ធទាំងសងខាងជាពាណិជ្ជករ ឬសហព័ទ្ធតែម្ខាងជាពាណិជ្ជករ ដោយបកស្រាយទាក់ទិននឹងការទទួលខុសត្រូវលើកាតព្វកិច្ច និងបំណុល។

ពាណិជ្ជករ គឺជារូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណា ដែលធ្វើពាណិជ្ជកិច្ច ហើយដែលពាណិជ្ជកិច្ចនោះធ្វើជារបរខ្លួនជាប្រចាំ។[42] ចំណែកពាណិជ្ជកិច្ច គឺជាសកម្មភាពទិញលក់ទំនិញ ឬសេវាដែលត្រូវបានអនុវត្តជាប្រចាំក្នុងគោលដៅធ្វើការដោះដូរ និងស្វែងរកប្រាក់ចំណេញ។[43] ដើម្បីអាចក្លាយជាពាណិជ្ជករបានលុះត្រាតែរូបវន្តបុគ្គល ឬនីតិបុគ្គលនោះធ្វើសកម្មភាពពាណិជ្ជកិច្ច ប៉ុន្តែមិនមែនគ្រប់សកម្មភាពនៃការទិញលក់ ឬដោះដូរទំនិញអាចចាត់ទុកជាពាណិជ្ជកិច្ចនោះទេ។ បើយោងតាមមាត្រា ២ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម សកម្មភាពដែលចាត់ទុកថាជាពាណិជ្ជកិច្ចរួមមាន ៖

- ការទិញដើម្បីលក់ទៅវិញ គិតបញ្ចូលទាំងក្នុងវិស័យអចលនទ្រព្យ
- រាល់សកម្មភាពនៃសហគ្រាសជួល សហគ្រាសការណកម្ម សហគ្រាសយកកំរៃជើងសារ សហគ្រាសដឹកជញ្ជូន សហគ្រាសបោះពុម្ពផ្សាយ និងសេវាដទៃទៀត
- ប្រតិបត្តិការនៃធនាគារប្តូររូបិយវត្ថុ

[42] ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម, លេខនស/រកម/០៦៩៥/០៤, ១៨វិច្ឆិកា ១៩៩៩, មាត្រា ១ (ចាប់ពីពេលនេះហៅថា ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម)។

[43] មាត្រា ១ ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម។

- ការផ្តល់សេវាអន្តរការ សេវាទីភ្នាក់ងារ ការិយាល័យសម្របសម្រួលកិច្ចការសេវាវប្បធម៌ និងការចាត់ចែងទស្សនីយភាពជាសាធារណៈ
- ប្រតិបត្តិការនៃសហគ្រាសសំណង់ ការទិញ ឬការជួលនាវាដឹកជញ្ជូន ក្នុងប្រទេស ឬក្រៅប្រទេស ការដឹកជញ្ជូន និងការផ្ញើបញ្ជូនតាមផ្លូវគោកផ្លូវទឹក និងផ្លូវអាកាស
- ការធានារ៉ាប់រងគ្រប់ប្រភេទ
- អាជីវកម្មនៃសាទ អាជីវកម្មព្រៃឈើ និងរ៉ែ។

ផ្ទុយមកវិញការផលិតដែលមិនមែនសម្រាប់លក់ទៅវិញ ឬការផលិត ឬសេវាទាំងឡាយ ដែលមានលក្ខណៈគ្រួសារ ឬការផលិតសិល្បៈសុទ្ធសាធ ឬការបង្ហាត់បង្រៀនដោយឯកជនផ្ទាល់ខ្លួន ឬដោយសហគមន៍ស្របច្បាប់មិនត្រូវចាត់ទុកជាពាណិជ្ជកិច្ចទេ ដូចនេះបុគ្គលដែលបានធ្វើនូវរាល់សកម្មភាពទាំងនេះ ក៏មិនត្រូវបានចាត់ទុកជាពាណិជ្ជករដែរ។[44]

សហព័ទ្ធនៃពាណិជ្ជករ ត្រូវចាត់ទុកថាជាពាណិជ្ជករដែរ បើសហព័ទ្ធនោះប្រកប ពាណិជ្ជកម្ម ដែលមានចុះបញ្ជីពាណិជ្ជកម្មដោយឡែក។[45] អានុភាពនៃអាពាហ៍ពិពាហ៍ពុំបានបើកសិទ្ធិឱ្យសហព័ទ្ធនៃពាណិជ្ជករដែលមិនបានចុះបញ្ជីក្លាយជាពាណិជ្ជករនោះទេ ទោះបីជាក្រមរដ្ឋប្បវេណី និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតបានបើកសិទ្ធិឱ្យសហព័ទ្ធគ្រប់គ្រងលើទ្រព្យសម្បត្តិរួម និងសិទ្ធិដទៃទៀតក៏ដោយ ប៉ុន្តែយោងតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម សហព័ទ្ធនៃពាណិជ្ជករ ត្រូវតែចុះបញ្ជីពាណិជ្ជកម្ម ទើបអាចទទួលស្គាល់ថាជាពាណិជ្ជករបាន។ ឧបមាថា ក្រុមហ៊ុនមួយដែលមានឈ្មោះសហព័ទ្ធទាំងសងខាង លុះត្រាតែការចុះបញ្ជីពាណិជ្ជកម្មនោះដាក់ឈ្មោះសហព័ទ្ធទាំងសង ព្រោះអានុភាពនៃអាពាហ៍ពិពាហ៍ ពុំអាចឱ្យសហព័ទ្ធម្ខាងទៀតក្លាយជាពាណិជ្ជករដោយស្វ័យប្រវត្តិបាននោះទេ។

តាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥ ទម្រង់ក្រុមហ៊ុន ត្រូវបែងចែកជាសាខាធំៗ ពីរៈ

១-ក្រុមហ៊ុនសហកម្មសិទ្ធិ (ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត)

២-ក្រុមហ៊ុនមូលធន (ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត)

ការទទួលខុសត្រូវរបស់ក្រុមហ៊ុនក្រោមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មមានពីរ គឺការទទួលខុសត្រូវមានកម្រិត និងការទទួលខុសត្រូវគ្មានកម្រិត។ ការទទួលខុសត្រូវគ្មានកម្រិតមានន័យថា ក្នុងករណីអាជីវកម្មមានការខាតបង់ ឬក្ស័យធន សហកម្មសិទ្ធិករទាំងឡាយ នៃក្រុមហ៊ុនត្រូវយកទ្រព្យសម្បត្តិផ្ទាល់ខ្លួនមកចាត់ចែងដើម្បីសងបំណុល។ ដោយឡែកការទទួលខុសត្រូវមានកម្រិត គឺសហកម្មសិទ្ធិករទទួលខុសត្រូវត្រឹមកម្រិតនៃភាគហ៊ុនដែល

[44] មាត្រា ៣ ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម។

[45] មាត្រា ៦ ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម។

ខ្លួនបានដាក់តែប៉ុណ្ណោះ។[46] ក្រុមហ៊ុនគឺមានកម្រិតត្រឹមតម្លៃជាវភាគហ៊ុន របស់ម្ចាស់ហ៊ុនម្នាក់ៗតែប៉ុណ្ណោះ ។ ក្រុមហ៊ុនមួយ គឺជានីតិបុគ្គលដាច់ដោយឡែកពីម្ចាស់ភាគហ៊ុនដែលដូច្នេះហើយ ការទទួលខុសត្រូវរបស់ម្ចាស់ភាគហ៊ុន លើបំណុលរបស់ក្រុមហ៊ុន គឺមានកម្រិតត្រឹមចំណែកភាគហ៊ុនរបស់ខ្លួនតែប៉ុណ្ណោះ។ នៅពេលដែលម្ចាស់ភាគហ៊ុនបានបង់ចំនួនទឹកប្រាក់ ដែលត្រូវទូទាត់សម្រាប់តម្លៃជាវភាគហ៊ុនពួកគេនឹងមិនទទួលខុសត្រូវលើចំនួនណាបន្ថែមទៀតឡើយ។ ប្រសិនបើក្រុមហ៊ុនត្រូវទទួលខុសត្រូវបំណុលណាមួយនោះ ការទទួលខុសត្រូវបែបនោះមិនមែនជាការទទួលខុសត្រូវរបស់ម្ចាស់ភាគហ៊ុននោះឡើយ។ ភាគហ៊ុនត្រូវបានការពារពីម្ចាស់បំណុលរបស់ក្រុមហ៊ុន និងហានិភ័យទាំងស្រុងនៃការបរាជ័យអាជីវកម្ម។ ការទទួលខុសត្រូវមានកម្រិតរបស់ភាគហ៊ុននេះមានទំនាក់ទំនង ជាពិសេសនៅពេលមាន ការរំលាយក្រុមហ៊ុន និងនៅពេលដែលប្រាក់ចំណេញទទួលបានពីទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន មិនគ្រប់គ្រាន់ក្នុងការទូទាត់បំណុលរបស់ក្រុមហ៊ុន។[47]

ក្នុងករណីដែលប្ដីប្រពន្ធបានចុះបញ្ជីពាណិជ្ជកម្មបង្កើតក្រុមហ៊ុនមួយជាមួយនឹងមិត្តិភក្តិដទៃទៀត ដែលមានឈ្មោះទាំងពីរនាក់ប្ដីប្រពន្ធជាកម្មសិទ្ធិករនៅក្នុងក្រុមហ៊ុននោះ រួចបានដាក់ទ្រព្យសម្បត្តិរួមដូចជាផ្ទះ និងដីមួយកន្លែងជាភាគហ៊ុននៅក្នុងក្រុមហ៊ុន។ ក្រុមហ៊ុនដែលបង្កើតឡើងនោះជាប្រភេទក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ដែលតម្រូវឱ្យមានសហកម្មសិទ្ធិករមានកម្រិតម្នាក់ ឬច្រើននាក់ ហើយសហព័ទ្ធទាំងពីរនាក់ជាសហកម្មសិទ្ធិករទទួលខុសត្រូវមានកម្រិត។[48] ប្រសិនបើក្រុមហ៊ុននោះក្ស័យធន សហព័ទ្ធទាំងពីរនាក់ទទួលខុសត្រូវត្រឹមចំណែកដែលពួកខ្លួនបានដាក់ភាគហ៊ុនតែប៉ុណ្ណោះ។[49] ផ្ទុយទៅវិញ បើសហព័ទ្ធទាំងពីរនាក់ជាសហកម្មសិទ្ធិទូទៅទទួលខុសត្រូវគ្មានកម្រិតនៅក្នុងក្រុមហ៊ុននោះ ពេលដែលក្រុមហ៊ុនក្ស័យធន សហព័ទ្ធទាំងពីរនាក់មានកាតព្វកិច្ចក្នុងការទូទាត់បំណុលលើសពីអ្វីដែលខ្លួនបានដាក់ទុន ក្នុងករណីដែលបំណុលរបស់ក្រុមហ៊ុនលើសពីទ្រព្យដែលក្រុមហ៊ុនមាន។[50] សហព័ទ្ធត្រូវធ្វើការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ ដើម្បីយកប្រាក់មកទូទាត់បំណុលទាំងអស់ដែលក្រុមហ៊ុននៅជំពាក់ម្ចាស់បំណុល។

---

[46] កញ្ញាមេធាវី ទ្រី ស្រីល័ក្ខណ និងកញ្ញា សរ ម៉ារីណា, ការទទួលខុសត្រូវរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត, ២៣ ធ្នូ ២០១៨, គេហទំព័រ http://freshnewsasia.com/index.php/en/localnews/108060-2018-12-23-03-20-01.html, ចូលទស្សនាថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១ ។

[47] កញ្ញាមេធាវី ទ្រី ស្រីល័ក្ខណ និងកញ្ញា សរ ម៉ារីណា, ការទទួលខុសត្រូវរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត, ២៣ ធ្នូ ២០១៨, គេហទំព័រ http://freshnewsasia.com/index.php/en/localnews/108060-2018-12-23-03-20-01.html, ចូលទស្សនាថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១ ។

[48] ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម, នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ៦៤ (ចាប់ពីពេលនេះហៅថា ច្បាប់ស្ដីពីសហគ្រាស ពាណិជ្ជកម្ម)។

[49] មាត្រា ៧២ ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម។

[50] មាត្រា ៧៥ ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម។

**ឧទាហរណ៍ ៖ សម្បត្តិ** និង**ធីតា** បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាក្នុងឆ្នាំ២០១៩។ បន្ទាប់ពីរៀបអាពាហ៍ពិពាហ៍រួចមក **សម្បត្តិ** និង**ធីតា** បានសម្រេចចិត្តបង្កើតក្រុមហ៊ុនមួយកន្លែងនៅក្នុងរាជធានីភ្នំពេញ។ **សម្បត្តិ** បានបបួលមិត្តភក្តិចំនួន០៣នាក់ទៀតដើម្បីដាក់ទុករកស៊ីជាមួយគ្នា ដោយមានដើមទុនសរុបចំនួន ១០០០០០$ (ដប់ម៉ឺនដុល្លាអាមេរិក) ហើយបានចុះកិច្ចសន្យារួមគ្នា ដោយកំណត់យ៉ាងច្បាស់ថា **សម្បត្តិ** និង**ធីតា** ជាសហកម្មសិទ្ធិករទទួលខុសត្រូវគ្មានកម្រិត ចំណែកឯមិត្តភក្តិ០៣នាក់ផ្សេងទៀតជាសហកម្មសិទ្ធិករទទួលខុសត្រូវមានកម្រិត។ ជាក់ស្តែងនៅក្នុងអំឡុងឆ្នាំ២០២១ ក្រោយពេលដែលជំងឺកូវីដ-១៩ បានរីករាលដាលនៅក្នុងសហគមន៍ ធ្វើឱ្យក្រុមហ៊ុនពុំមានប្រាក់ចំណូលជាច្រើនខែ ហើយសហកម្មសិទ្ធិករទាំងអស់ក៏បានសម្រេចចិត្តប្រកាសក្ស័យធន។ បន្ទាប់ពីប្រកាសក្ស័យធន បំណុលដែលក្រុមហ៊ុនជំពាក់សរុបមានចំនួន ១៥០០០០$ (ដប់ប្រាំម៉ឺនដុល្លាអាមេរិក)។

ក្នុងករណីខាងលើនេះ ចំពោះសហកម្មសិទ្ធិករទទួលខុសត្រូវមានកម្រិត គឺទទួលខុសត្រូវចំពោះបំណុលត្រឹមចំណែកដែលខ្លួនបានដាក់ភាគហ៊ុនប៉ុណ្ណោះ។ ចំណែក **សម្បត្តិ** និង**ធីតា** ដែលជាសហកម្មសិទ្ធិទូទៅទទួលខុសត្រូវគ្មានកម្រិតវិញ គឺត្រូវទទួលខុសត្រូវលើសពីចំណែកដែលខ្លួនបានដាក់ទុន ពោលគឺ **សម្បត្តិ** និង**ធីតា** ត្រូវយកទ្រព្យសម្បត្តិរួមដែលខ្លួនមានយកមកសងបំណុលទាំងអស់។ ប្រសិនជា **សម្បត្តិ** និង**ធីតា** បានលក់នូវទ្រព្យសម្បត្តិរួមដែលខ្លួនមានអស់ហើយ ប៉ុន្តែនៅតែមិនអាចសងបំណុលរបស់ក្រុមហ៊ុនគ្រប់នោះ គឺច្បាប់កំណត់សងម្ចាស់បំណុលតាមលំដាប់ ដោយ **សម្បត្តិ** និង**ធីតា**ពុំជាប់កាតព្វកិច្ចទៀតនោះទេ ថ្វីបើ**សម្បត្តិ** និង**ធីតា**នៅមានទ្រព្យដោយឡែកផ្សេងទៀតដែលមិនទាន់លក់ ព្រោះ **សម្បត្តិ** និង**ធីតា** យកទ្រព្យសម្បត្តិរួមដាក់ជាដើមទុន មិនបានយកទ្រព្យដោយឡែកមកដាក់ជាដើមទុននោះទេ ដូចនេះ**សម្បត្តិ** និង**ធីតា** អាចរក្សាទុកទ្រព្យដោយឡែកដោយមិនចាំបាច់លក់មិនសងបំណុលនោះទេ។[51]

ម្យ៉ាងវិញទៀតបើសហព័ទ្ធតែម្ខាងជាពាណិជ្ជករ ហើយសហព័ទ្ធម្ខាងទៀតមិនមែនជាពាណិជ្ជករនោះគឺយើងត្រូវមើលលើប្រភេទទ្រព្យ ដែលសហព័ទ្ធម្ខាងបានដាក់ទុននៅពេលដែលចុះកិច្ចសន្យាបង្កើតក្រុមហ៊ុននោះ។ ប្រសិនបើសហព័ទ្ធបានយកទ្រព្យដោយឡែកដែលខ្លួនមានមុនពេលរៀបអាពាហ៍ពិពាហ៍ ឬទ្រព្យដែលបានមកតាមរយៈប្រទានកម្ម ឬអច្ច័យទាន ឬអំណោយក្នុងពេលរៀបអាពាហ៍ពិពាហ៍នោះ ចំពោះករណីយកិច្ចលើបំណុល គឺម្ចាស់បំណុលអាចរឹបអូសតែត្រឹមទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធតែម្ខាងតែប៉ុណ្ណោះ រីឯទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធទាំងសងខាងវិញគឺមិនអាចយកមកឆ្លើយតបនឹងបំណុលរបស់ក្រុមហ៊ុននោះទេ។

**ឧទាហរណ៍ ៖** ក្រុមហ៊ុនឯកបុគ្គលទទួលខុសត្រូវមានកម្រិតរបស់លោក **ក** មានដើមទុនសរុប ២០០,០០០ ដុល្លារអាមេរិក ដែលលោក **ក** គឺជាម្ចាស់ភាគហ៊ុន១០០ ភាគរយ បានចុះកិច្ចសន្យាដឹកជញ្ជូនទំនិញទៅបរទេសជាមួយក្រុមហ៊ុន B ចាប់តាំងពីឆ្នាំ២០១៥ ។ ក្នុងប្រតិបត្តិការរបស់ខ្លួន ក្រុមហ៊ុនឯកបុគ្គលទទួលខុសត្រូវមានកម្រិតរបស់លោក **ក** បានខាតបង់ប្រាក់អស់ជាច្រើន រហូតដល់លែងមានលទ្ធភាពបន្តដំណើរការក្រុមហ៊ុនទៀតបានទើប

[51] មាត្រា ១៤៧ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។

បានសម្រេចចិត្តបិទក្រុមហ៊ុន ។ ក្នុងពេលសហការជាមួយក្រុមហ៊ុនដឹកជញ្ជូន B ក្រុមហ៊ុនឯកបុគ្គលទទួលខុសត្រូវមានកម្រិតរបស់លោក **ក** បានជំពាក់បំណុល ក្រុមហ៊ុនដឹកជញ្ជូន B រហូតដល់ ៤០០,០០០ ដុល្លារអាមេរិក ។ យោងតាមស្មារតី មាត្រា ១៤៧ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម លោក **ក** ដែលជាភាគហ៊ុននិកតែម្នាក់ របស់ក្រុមហ៊ុនឯកជនបុគ្គលទទួលខុសត្រូវមានកម្រិត ត្រឹមកម្រិតភាគហ៊ុនដែលគាត់មានតែប៉ុណ្ណោះ ពោលគឺក្រុមហ៊ុន B ដែលម្ចាស់បំណុល ទទួលបានត្រឹមតែកម្រិតភាគហ៊ុនរបស់លោក **ក** ដែលមានក្នុងដើមទុនរបស់ក្រុមហ៊ុន និងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនតែប៉ុណ្ណោះ ហើយក្រុមហ៊ុន B ពុំមានសិទ្ធិធ្វើការទាមទារទ្រព្យសម្បត្តិឯកជនរបស់លោក **ក** ឡើយ ។[52]

សរុបមកសារៈសំខាន់នៃការបែងចែកទ្រព្យសម្បត្តិរបស់សហព័ទ្ធ វាផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនចំពោះសហព័ទ្ធដែលជាពាណិជ្ជករចំពោះសិទ្ធិ និងករណីយកិច្ចលើបំណុល ព្រោះវាអាចកម្រិតនូវការទទួលខុសត្រូវរបស់សហព័ទ្ធ នៅពេលដែលក្រុមហ៊ុនក្ស័យធន និងផ្តល់នូវការសង្គ្រោះដល់សហព័ទ្ធក្រោយពេលដែលជួបបញ្ហាក្ស័យធន ពោលគឺសហព័ទ្ធទាំងសងខាងនៅតែទ្រទ្រង់ជីវភាពគ្រួសារបានបន្តទៀត ដោយនៅសល់ចំណែកទ្រព្យដែលមិនបានដាក់បញ្ចូលទៅក្នុងភាគហ៊ុនរបស់ក្រុមហ៊ុន។

## ៦. សហព័ទ្ធជាជនបរទេស

ការរៀបអាពាហ៍ពិពាហ៍នៅក្នុងប្រទេសកម្ពុជា ក្រៅការរៀបអាពាហ៍ពិពាហ៍រវាងប្តីប្រពន្ធទាំងពីរនាក់ដែលជាជនជាតិខ្មែរ ឬមានសញ្ជាតិខ្មែរទាំងពីរនាក់នោះ គឺនៅមានការរៀបអាពាហ៍ពិពាហ៍រវាងបុរស និងស្ត្រី ដែលមិនមែនជាជនជាតិខ្មែរ ឬមិនមានសញ្ជាតិខ្មែរពីកំណើត ដែលជាការរៀបអាពាហ៍ពិពាហ៍រវាងខ្មែរ និងជនបរទេស ដោយការរៀបអាពាហ៍ពិពាហ៍នោះ ត្រូវតែស្របតាមគោលការណ៍នៃច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា និងតម្រូវឱ្យជនបរទេសដែលអាចសុំទាមទារសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍បានត្រូវបំពេញលក្ខខណ្ឌដូចជាៈ[53]

- មានគំនិត មារយាទ និងសីលធម៌ល្អ
- ពុំដែលមានទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ
- មានទីលំនៅក្នុងព្រះរាជាណាក្រកម្ពុជា នៅពេលដាក់ពាក្យសុំទាមទារសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍
- ចេះនិយាយភាសាខ្មែរ ចេះអក្សរខ្មែរ និងយល់ដឹងប្រវត្តិសាស្ត្រខ្មែរខ្លះៗ
- មានបញ្ញា និងកាយសម្បទាដែលមិននាំឱ្យមានគ្រោះថ្នាក់ ឬនាំឱ្យមានបន្ទុកដល់ជាតិ

[52] កញ្ញាមេធាវី ទ្រី ស្រីល័ក្ខណ និងកញ្ញា សរ ម៉ារីណា, ការទទួលខុសត្រូវរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត, ២៣ ធ្នូ ២០១៨, គេហទំព័រ http://freshnewsasia.com/index.php/en/localnews/108060-2018-12-23-03-20-01.html, ចូលទស្សនាថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១ ។

[53] មាត្រា ១២ ច្បាប់ស្តីពីសញ្ជាតិ, លេខ នស/រកម/០៦១៨/០០៨, ២១ មិថុនា ២០១៨។

ក្រៅពីនេះការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស គឺត្រូវបានបំពេញបែបបទមួយចំនួនជាចាំបាច់ទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា[54] ដើម្បីឱ្យក្រសួងមានសមត្ថកិច្ចធ្វើការទទួលស្គាល់ និងអនុញ្ញាតឱ្យជនបរទេសដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ ។

ជាទូទៅក្នុងការកសាងគ្រួសារមួយដោយមានសហព័ទ្ធម្ខាងជាជនបរទេស គឺសុទ្ធសឹងតែត្រូវគោរពប្រតិបត្តិតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដូចទៅនឹងការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរដែរ គ្រាន់តែមានចំណុចមួយចំនួនដែលជនបរទេសដែលរស់នៅលើទឹកដីកម្ពុជា ពុំអាចមានសិទ្ធិគ្រប់គ្រាន់ដូចទៅនឹងជនជាតិខ្មែរទេ ទោះបីជាបានរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋដែលមានសញ្ជាតិខ្មែររួចក៏ដោយ។ ការរៀបអាពាហ៍ពិពាហ៍រួច គឺត្រូវជាប់នូវសិទ្ធិ និងករណីយកិច្ចដែលមាននូវទ្រព្យសម្បត្តិក្នុងអំឡុងអាពាហ៍ពិពាហ៍ ព្រមទាំងបំណុលរួម និងបំណុលដោយឡែកផងដែរ។

ទ្រព្យសម្បត្តិដែលកើតក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ក្នុងលក្ខខណ្ឌដែលសហព័ទ្ធម្ខាងជាជនបរទេសដែលក្នុងនេះជនបរទេសនោះ គឺអាចមានសិទ្ធិក្នុងទិញ-លក់បានមានតែទ្រព្យណាដែលជាចលនទ្រព្យ តែមិនអាចធ្វើការទិញ-លក់លើអចលនទ្រព្យបានទេ តួយ៉ាងដូចជាដីធ្លី និងផ្ទះសម្បែងជាដើម។ យោងតាមមាត្រា ៨ កថាខណ្ឌ ១ ច្បាប់ភូមិបាលនៃព្រះរាជាណាចក្រកម្ពុជា បានបង្ហាញយ៉ាងច្បាស់ថា មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីនៃព្រះរាជាណាចក្រកម្ពុជា។[55] ប៉ុន្តែក្នុងករណីដែលជនបរទេសបានក្លែងបន្លំប័ណ្ណសញ្ជាតិដើម្បីឱ្យក្លាយជាកម្មសិទ្ធិករលើដីនៅកម្ពុជានឹងត្រូវផ្តន្ទាទោស ដោយទ្រព្យដែលបានមកក្នុងលក្ខខណ្ឌនេះត្រូវរឹបអូសយកទុកជាសម្បត្តិរដ្ឋ ដោយរដ្ឋមិនចេញសំណងឱ្យឡើយ។[56] តែក្នុងលក្ខខណ្ឌនេះ សហព័ទ្ធម្ខាងទៀតដែលមានសញ្ជាតិខ្មែរ អាចមានសិទ្ធិក្នុងការកាន់កាប់ ក៏ដូចជាការទិញលក់អចលនទ្រព្យ[57] ដោយអាចនឹងធ្វើជាអ្នកតំណាងឱ្យសហព័ទ្ធដែលជាជនបរទេសបាន ។

ប្រសិនក្នុងករណីដែលសហព័ទ្ធទាំងពីរបានលែងលះពីគ្នា គឺច្បាស់ណាស់ត្រូវមានការបែងចែកទៅលើទ្រព្យសម្បត្តិរួម និងដោយឡែករបស់សហព័ទ្ធទាំងសងខាង ក៏ដូចជាក្នុងលក្ខខណ្ឌខ្លះអាចនៅជាប់នូវបំណុលរួម និងបំណុលដោយឡែកផងដែរ ។ ទាក់ទងនឹងបំណុលរួមលើករណីដែលសហព័ទ្ធម្ខាងជាជនបរទេស និងសហព័ទ្ធម្ខាងទៀតជាជនជាតិខ្មែរនោះ គឺយើងអាចដឹងហើយថា អាពាហ៍ពិពាហ៍នេះអាចបន្សល់ទុកនូវទ្រព្យរួមដែលអាចជា

---

[54] មាត្រា ៦ នៃអនុក្រឹត្យស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស, លេខ ១៨៨ អនក្រ.បក , ០៣ វិច្ឆិកា ២០០៨។

[55] មាត្រា ៨ កថាខណ្ឌ ១ ច្បាប់ភូមិបាលនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១ (ចាប់ពីពេលនេះហៅថា ច្បាប់ភូមិបាល ២០០១)។

[56] មាត្រា ៨ កថាខណ្ឌ ៣ ច្បាប់ភូមិបាល ២០០១។

[57] មាត្រា ៦៦ ច្បាប់ភូមិបាល ២០០១។

ចលនទ្រព្យ ឬអចលនទ្រព្យ ដើម្បីទុកសម្រាប់ឆ្លើយតបទៅនឹងបំណុលរួមដែលខ្លួនមាន ។ ចំពោះចលនទ្រព្យ គឺត្រូវបានគិតគូក្នុងការសងជាធម្មតា ដូចទៅនឹងអាពាហ៍ពិពាហ៍របស់សហព័ទ្ធទាំងសងខាងជាជនជាតិខ្មែរដូចគ្នាដែរ ពោលគឺសហព័ទ្ធជាជនជាតិបរទេសមានសិទ្ធិក្នុងការធ្វើការចាត់ចែង ។ យ៉ាងណាមិញ ចំពោះអចលនទ្រព្យ ដែលមានដូចជាដីធ្លី ផ្ទះសម្បែងជាដើម គឺមានតែមានសហព័ទ្ធដែលមានសញ្ជាតិខ្មែរតែប៉ុណ្ណោះអាចនឹងមានសិទ្ធិជាកម្មសិទ្ធិលើអចលនទ្រព្យលើដីនៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែចំពោះសហព័ទ្ធដែលជាជនបរទេស គឺពុំមានសិទ្ធិក្នុងការទិញ-លក់នោះទេ ហេតុដូចនេះតុលាការ អាចធ្វើការពិចារណាក្នុងការចេញសេចក្តីសម្រេច ចំពោះការឆ្លើយតបទៅនឹងបំណុលរួម ដែលសហព័ទ្ធដែលជាជនបរទេសពុំមានសិទ្ធិលើអចលទ្រព្យនោះ ដើម្បីឱ្យមានភាពសុក្រឹត្យមិនលំអៀង ។

**ឧទាហរណ៍ ៖** អាពាហ៍ពិពាហ៍មួយដែលមានស្វាមីជាជនបរទេស និងភរិយាជាជនជាតិខ្មែរ ដែលបានរៀបអាពាហ៍ពិពាហ៍នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងអំឡុងពេលរៀបការរួច សហព័ទ្ធទាំងសងខាងបានខិតខំប្រកបមុខរបររកស៊ី រហូតបានទិញនូវដីមួយកន្លែង ដែរក្នុងការទិញដីនេះ មានប្រពន្ធដែលជាជនជាតិខ្មែរតែម្នាក់គត់ដែលអាចមានឈ្មោះជាម្ចាស់កម្មសិទ្ធិនៃដីនោះបាន។ ក្រោយមកមិនបានប៉ុន្មានប្តីប្រពន្ធទាំងពីរនាក់ ក៏បានរកស៊ីខាត ព្រមទាំងជួបនូវវិបត្តិសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ ដែលឈានទៅដល់ការយកដីដែលខ្លួនមាននោះ ទៅដាក់បញ្ចាំនៅធនាគារមួយកន្លែង ដើម្បីយកលុយពីការដាក់បញ្ចាំដីនោះមកដោះស្រាយជីវភាព។ រំលងមកជាច្រើនខែដែលជាប់នូវបំណុលរួមនោះ មិនយូរប៉ុន្មានប្តីប្រពន្ធទាំងពីរនាក់នោះក្នុងការរស់នៅមិនចុះសម្រុងនឹងគ្នា ដែលមិនអាចបន្តរស់នៅជាមួយគ្នាបាន ក៏បានសម្រេចចិត្តលែងលះគ្នា ដោយការលែងលះនេះត្រូវបែងចែកទៅលើទ្រព្យសម្បត្តិ ដែលមានក្នុងកម្មវត្ថុនៃបណ្តឹងគឺបែងចែកទ្រព្យជាពីរស្មើៗគ្នា និងគិតលើបំណុលរួមដែលខ្ចីធនាគារលើដីដាក់បញ្ចាំ ។ ក្នុងករណីនេះតុលាការអាចសម្រេចចេញសាលក្រមក្នុងការលែងលះ ដោយស្របតាមកម្មវត្ថុនៃការទាមទារដែលបែងចែកទ្រព្យស្មើៗគ្នា ពាក់កណ្តាលម្នាក់ ។ ចំណែកឯបំណុលរួមវិញ តុលាការអាចពិចារណាលើបំណុលរួម ដែលសហព័ទ្ធដែលជាជនបរទេសពុំសិទ្ធិលើអចលទ្រព្យដាក់បញ្ចាំដែលជាដីនោះ ដើម្បីមានការទូរទាត់សងមួយដ៏សមស្រប និងគោរពតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

## ៧. របបសន្តតិកម្ម

របបសន្តតិកម្មនៅលើពិភពលោកនេះអាចចែកចេញជាពីរប្រភេទបាន គឺគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ និងគោលការណ៍ជម្រះបញ្ជី។ គោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ គឺជាគោលការណ៍ដែលសន្តតិជនត្រូវទទួលទាំងស្រុងនូវសិទ្ធិ និងករណីយកិច្ចទាំងអស់របស់មតកជន។ ប៉ុន្តែក្នុងករណីដែលមតកជននោះបានបន្សល់នូវកាតព្វកិច្ចច្រើនពេក ប្រសិនបើសន្តតិជនទទួលបន្តនូវកាតព្វកិច្ចទាំងនោះនឹងធ្វើឱ្យខូចប្រយោជន៍យ៉ាងធ្ងន់ធ្ងរដោយសារសន្តតិកម្ម ដូច្នេះហើយច្បាប់បានបញ្ញត្តិពីរបបបោះបង់នូវសន្តតិកម្ម ឬការយល់ព្រមដោយមានកម្រិត ដើម្បីជៀសវាងនូវស្ថានភាពនេះ។ ចំណែកគោលការណ៍ជម្រះបញ្ជី គឺត្រូវជម្រះបញ្ជីទាំងអស់នូវសិទ្ធិលើ

បំណុល និងកាតព្វកិច្ចរបស់មតកជន ពេលដែលសន្តតិកម្មកើតមានឡើង ហើយសន្តតិជននឹងស្នងទ្រព្យនោះតែក្នុងករណីដែលមានទ្រព្យសកម្មប៉ុណ្ណោះ ហើយក្នុងករណីដែលមានកាតព្វកិច្ចធ្ងន់ធ្ងរហួសហេតុ ត្រូវប្រកាសធនក្ស័យនៃមត៌កនោះ ដើម្បីកុំឱ្យសន្តតិជនទទួលនូវបន្ទុកកាតព្វកិច្ចនោះ។ ដោយគោលការណ៍ជម្រះបញ្ជីមាននីតិវិធីស្មុគស្មាញអស់សោហ៊ុយ និងចំណាយពេលវេលាច្រើន ទើបក្រមរដ្ឋប្បវេណីយើងបានបញ្ញត្តិដោយយកគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិមកធ្វើជាមូលដ្ឋាន។[58]

សន្តតិកម្មត្រូវចាប់ផ្តើមឡើងដោយមរណភាពរបស់មតកជន។[59] ក្នុងករណីដែលបុគ្គលណាម្នាក់ៗបានទទួលប្រកាសអំពីការបាត់ខ្លួន ត្រូវចាត់ថាអ្នកនោះបានទទួលមរណភាពដោយផ្អែកលើមាត្រា ៤៣ នៃក្រមរដ្ឋ-ប្បវេណី ដូច្នេះហើយសន្តតិកម្មត្រូវចាប់ផ្តើម។ សន្តតិកម្មត្រូវបានបែងចែកជាពីរ គឺសន្តតិកម្មតាមច្បាប់ និងសន្តតិកម្មមានបណ្តាំ។[60] សន្តតិកម្មមានបណ្តាំគឺធ្វើតាមឡើងតាមឆន្ទៈរបស់មតកជន ដោយមានមតកសាសន៍ត្រឹម ចំណែកសន្តតិកម្មតាមច្បាប់អនុវត្តក្នុងករណីដែលគ្មានមតកសាសន៍។ មតកសាសន៍មិនមែនជាប្រទានកម្មមួយប្រភេទទេ គឺត្រូវចាត់ទុកជាសន្តតិកម្មតែម្តង ហេតុនេះហើយគួរតែវាយតម្លៃថា ការធ្វើអនុប្បទាននូវទ្រព្យសម្បត្តិដោយមតកសាសន៍ ចំពោះសន្តតិជន គឺជាការកំណត់ចំណែកមត៌ក ព្រមទាំងកំណត់នូវនីតិវិធីបែងចែកមត៌ក។[61] សន្តតិជនត្រូវទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចទាំងអស់ដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិរបស់មតកជន ចាប់ពីពេលដែលចាប់ផ្តើមសន្តតិកម្ម។[62] ក្នុងករណីមានសន្តតិជនច្រើននាក់ សហសន្តតិជនម្នាក់ៗត្រូវទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចតាមសមាមាត្រនៃចំណែកមត៌កនោះ។[63] ប្រសិនបើមតកជនមានកាតព្វកិច្ចចំពោះតតិយជន ហើយបើកាតព្វកិច្ចនោះជាប្រាក់ ជាអាទិ៍ ត្រូវបែងចែកតាមចំណែកមត៌កដែលច្បាប់បានកំណត់។ ម្យ៉ាងវិញទៀតប្រសិនបើសហសន្តតិជនមិនបានបោះបង់ចោលការស្នងនោះទេ ត្រូវទទួលករណីយកិច្ចសងកាតព្វកិច្ចរបស់មតកជន ទៅតាមសមាមាត្រនៃចំណែកមត៌កដែលច្បាប់បានកំណត់ លើកលែងតែសហសន្តតិជនមិនបានបោះបង់សន្តតិកម្មនោះ។[64]

កូនរបស់មតកជនត្រូវក្លាយជាសន្តតិជនដែលមានលំដាប់ទី១។[65] កូនរបស់មតកជនមានន័យថា កូនដែលមានបុត្តភាពត្រូវបានទទួលស្គាល់តាមផ្លូវច្បាប់។ ដូច្នេះចំពោះកូនក្រៅអាពាហ៍ពិពាហ៍ ទោះបីជាមានទំនាក់ទំនងបិតុភាពបង្កើតក៏ដោយ ប្រសិនបើទំនាក់ទំនងនោះមិនត្រូវបានទទួលស្គាល់ទេ បុត្តភាពតាមផ្លូវច្បាប់ក៏មិនអាច

---

[58] សេចក្តីកំណត់មាត្រានីមួយៗក្រមរដ្ឋប្បវេណី, គន្លឹះទី៨ ដល់គន្លឹះទី៩, ទំព័រទី ១។

[59] មាត្រា ១១៩៥ កថាខណ្ឌទី ១ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ។

[60] មាត្រា ១១៩៥ កថាខណ្ឌទី ២ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ។

[61] សេចក្តីកំណត់មាត្រានីមួយៗក្រមរដ្ឋប្បវេណី, គន្លឹះទី៨ ដល់គន្លឹះទី៩, ទំព័រទី ១។

[62] មាត្រា ១១៩៧ កថាខណ្ឌទី ១ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ។

[63] មាត្រា ១១៩៨ កថាខណ្ឌទី ១ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ។

[64] សេចក្តីកំណត់មាត្រានីមួយៗក្រមរដ្ឋប្បវេណី, គន្លឹះទី៨ ដល់គន្លឹះទី៩, ទំព័រទី ៤ និងទី៥។

[65] មាត្រា ១១៥៦ កថាខណ្ឌទី ១ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ។

ទទួលស្គាល់បានដែរ ដូច្នេះកូននោះមិនអាចក្លាយជាសន្តតិជនរបស់ឪពុកបានទេ។ ហើយចំពោះកូនដែលត្រូវបានសុំតាមសុំកូនពេញលេញ ញាតិភាពតាមផ្លូវច្បាប់ជាមួយនឹងឪពុកម្តាយបង្កើតត្រូវបានបញ្ចប់ ដោយយោងតាមមាត្រា ១០១៤ ក្រមរដ្ឋប្បវេណី ដូច្នេះកូននោះមិនអាចទទួលសន្តតិកម្មបានទេ ពោលគឺគេអាចទទួលសន្តតិកម្មតែពីឪពុកម្តាយចិញ្ចឹមប៉ុណ្ណោះ។ រីឯកូនសុំតាមសុំកូនធម្មតាវិញ អាចទទួលសន្តតិកម្មពីឪពុកម្តាយបង្កើតផង និងពីឪពុកម្តាយចិញ្ចឹមផង ដោយយោងតាមមាត្រា ១០២៦ ក្រមរដ្ឋប្បវេណី។[66] ម្យ៉ាងវិញទៀតសហព័ទ្ធរបស់មតកជនត្រូវក្លាយជាសន្តតិជនជានិច្ច ទោះបីជាមាន ឬគ្មានសន្តតិជនផ្សេងទៀតក៏ដោយ។[67] ពាក្យថា "ជានិច្ច" នៅក្នុងនេះមានន័យថា គ្មានពាក់ព័ន្ធនឹងអត្ថិភាពរបស់សន្តតិជនផ្សេង ព្រមទាំងលំដាប់សន្តតិកម្ម។[68] ឧទាហរណ៍ ក្នុងករណីដែលមតកជនមានកូន ឬមានសន្តតិជនជំនួសកូននោះ សហព័ទ្ធត្រូវទទួលសន្តតិកម្មជាមួយបុគ្គលនោះ។ ប្រសិនបើមតកជនគ្មានសន្តតិជនពីលំដាប់ទី១ ដល់លំដាប់ទី៣ទេ សហព័ទ្ធនឹងទទួលសន្តតិកម្មតែម្នាក់ឯង ដោយយោងតាមបញ្ញត្តិនៃមាត្រា ១១៦១ កថាខណ្ឌ ១ ក្រមរដ្ឋប្បវេណី។

ក្នុងករណីដែលបុគ្គលច្រើននាក់បានទទួលមរណភាព តែមិនដឹងថា បុគ្គលណាបានទទួលមរណភាពមុន ឬក្រោយនោះ ត្រូវចាត់ទុកថា បុគ្គលទាំងនោះបានទទួលមរណភាពព្រមគ្នា។[69] ឧទាហរណ៍ ក្នុងករណីដែលយន្តហោះធ្លាក់ ហើយឪពុក និងកូនដែលបានជិះយន្តហោះនោះបានទទួលមរណភាព ត្រូវចាត់ទុកថាឪពុក និងកូនោះបានទទួលមរណភាពព្រមគ្នា។ ការបង្កើតបញ្ញត្តិរបៀបនេះ គឺដើម្បីដោះស្រាយឱ្យបានសមរម្យនូវបញ្ហាសន្តតិកម្ម។ ក្នុងឧទាហរណ៍ខាងលើនេះដែលក្រុមគ្រួសារមួយមានប្តីប្រពន្ធ និងកូនម្នាក់ កូននោះនៅក្មេង ហើយមិនទាន់មានកូនទេ ថែមទាំងគ្មានទ្រព្យសម្បត្តិទៀត ឪពុកម្តាយខាងប្តីក៏នៅមានសុខភាពល្អ។ ក្នុងករណីដែលឪពុក និងកូនបានទទួលមរណភាព តើអ្នកណាទទួលមរណភាពមុន អ្នកណាទទួលមរណភាពក្រោយនោះ លទ្ធផលនៃសន្តតិកម្មខុសគ្នាខ្លាំង។ ប្រសិនបើប្តីបានទទួលមរណភាពមុន ប្រពន្ធនឹងទទួលទ្រព្យពាក់កណ្តាល ដោយសន្តតិកម្ម ហើយកូនក៏បានទទួលពាក់កណ្តាលដូចគ្នាដែរ ដោយអនុឡោមតាមមាត្រា ១១៦២ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី។ បន្ទាប់មកកូនបានទទួលមរណភាព ហើយពេលនោះប្រពន្ធនឹងបានទទួលទ្រព្យពីកូនទាំងអស់ដោយសន្តតិកម្មតាមមាត្រា ១១៥៩ កថាខណ្ឌ១ ក្រមរដ្ឋប្បវេណី ដោយលទ្ធផលគឺប្រពន្ធបានទទួលទ្រព្យទាំងអស់ពីប្តី។ ផ្ទុយទៅវិញ ប្រសិនបើកូនបានទទួលមរណភាពមុន ប្រពន្ធ និងឪពុកម្តាយរបស់ប្តីនឹងទទួលម្នាក់ មួយភាគបី ដោយសន្តតិកម្ម (មាត្រា ១១៦២ កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណី)។ ក្នុងស្ថានភាពនេះ ការបង្កើតនូវហេតុការណ៍កាន់កាប់ទ្រព្យសម្បត្តិមុន ជាការមួយដែលអ្នកកាន់កាប់អាចចំណេញជាងគេ នេះគឺដោយសារតែបុគ្គលដែលចង់បដិសេធនូវហេតុការណ៍បានសម្រេចនោះ ត្រូវធ្វើការបញ្ជាក់ភស្តុតាងយ៉ាងសកម្មថា តើអ្នកណាបានទទួលមរណភាពមុន ក៏ប៉ុន្តែតាមធម្មតា

[66] សេចក្តីកំណត់មាត្រានីមួយៗក្រមរដ្ឋប្បវេណី, គន្លឹះទី៨ ដល់គន្លឹះទី៩, ទំព័រទី ១៤។

[67] មាត្រា ១១៦១ កថាខណ្ឌទី ១ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ។

[68] សេចក្តីកំណត់មាត្រានីមួយៗក្រមរដ្ឋប្បវេណី, គន្លឹះទី៨ ដល់គន្លឹះទី៩, ទំព័រទី ២៥។

[69] មាត្រា ៤៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ។

មិនងាយធ្វើបានឡើយ។ ដូច្នេះហើយដើម្បីជៀសវាងកុំឱ្យមានបញ្ហាអ្នកធ្វើមុនជាអ្នកឈ្នះ យោងតាមមាត្រា ៤៥ ក្រមរដ្ឋប្បវេណី ប្រសិនបើបានទទួលមរណភាពព្រមគ្នាទៅ បុគ្គលដែលបានទទួលមរណភាពព្រមគ្នានេះ មិនអាចធ្វើសន្តតិកម្មបានទេ ដូចនេះកូនមិនអាចធ្វើសន្តតិកម្មទ្រព្យសម្បត្តិរបស់ឪពុកបានទេ ហើយប្រពន្ធ និងឪពុកម្តាយរបស់ប្តីនឹងបានទទួល១ ភាគ ៣ ក្នុងម្នាក់ៗ។

**ឧទាហរណ៍ ៖ សៅ** និង **កញ្ញា** បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នារយៈពេល០២ឆ្នាំមកហើយ ប៉ុន្តែពុំមានកូនឡើយ។ ក្នុងអំឡុងពេលនៃអាពាហ៍ពិពាហ៍នេះ **សៅ** និង**កញ្ញា** បានទិញផ្ទះមួយកន្លែង និងបានបង់រំលោះដីមួយកន្លែង ព្រមទាំងរថយន្តមួយគ្រឿងទៀតជាមួយធនាគារ។ ក្រោយមកដោយសារប្រទេសមានសង្គ្រាម **សៅ** ដែលជាកងទ័ព ក៏បានទៅបំពេញកាតព្វកិច្ចការពារមាតុភូមិ។ មួយឆ្នាំបន្ទាប់ពីសង្គ្រាមបានបញ្ចប់ទៅ **កញ្ញា** មិនឃើញប្តីត្រឡប់មកវិញឡើយ។ ក្នុងរយៈពេលដែលប្តីបានទៅធ្វើសង្គ្រាមនោះ **កញ្ញា** ពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការសងបំណុលទៅធនាគារ និងថែមទាំងមានការខ្វះខាតក្នុងការថែទាំផ្ទះសម្បែងទៀតផង ទើប **កញ្ញា** សម្រេចចិត្តខ្ចីប្រាក់មួយចំនួនពីមិត្តភក្តិរបស់នាង។ តើ **កញ្ញា** មានដំណោះស្រាយអ្វីដើម្បីអាចសម្រាលបន្ទុកនៃបំណុលដែលខ្លួនកំពុងតែទទួលខុសត្រូវក្នុងពេលបច្ចុប្បន្ន?

ស្របតាមមាត្រា ៤៣ ក្រមរដ្ឋប្បវេណី បានចែងថា ក្នុងអំឡុងពេល ០១ឆ្នាំ ក្រោយពីចប់សង្គ្រាម ហើយពុំមានដំណឹងច្បាស់លាស់ថា បុគ្គលដែលអវត្តមាននៅរស់ ឬទទួលមរណភាព នោះ ត្រូវបានសន្មតថា អ្នកបាត់ខ្លួននោះបានទទួលមរណភាព។ ដូចនេះ **សៅ** ត្រូវបានចាត់ទុកថាបានទទួលមរណភាព ក្រោយពីមិនបានវិលត្រឡប់មកផ្ទះវិញ បន្ទាប់ពីសង្គ្រាមបានកន្លងផុតទៅ០១ឆ្នាំ។ របបសន្តតិកម្មត្រូវបានចាប់ផ្តើម ក្រោយពេលតុលាការប្រកាសអំពីការបាត់ខ្លួនរបស់ **សៅ**។ ដោយហេតុថា **សៅ** ពុំមានបញ្ញាញាតិនោះទេ ថែមទាំងពុំមានសន្តតិជនលំដាប់ទី១ ទៀតផង ដូចនេះទ្រព្យសម្បត្តិទាំងអស់ក្លាយជាកម្មសិទ្ធិរបស់ **កញ្ញា**។ **កញ្ញា** អាចដាក់លក់ផ្ទះដែលជាទ្រព្យរបស់ប្តីប្រពន្ធ ដើម្បីយកលុយមកសងបំណុលដែលខ្លួនបានជំពាក់ និងបង់ទៅធនាគារតាមចំនួនជាក់ស្តែងក្រោយពីលក់ផ្ទះនោះ។ ចំពោះបំណុលដែលនៅសេះសល់ គឺ **កញ្ញា** ត្រូវរ៉ាប់រងម្នាក់ឯងរហូតដល់កាតព្វកិច្ចត្រូវបានបំពេញរួចរាល់។ ផ្ទុយទៅវិញ ប្រសិនបើ **សៅ** បានត្រឡប់មកវិញ ហើយត្រូវបានតុលាការសម្រេចលុបចោលការប្រកាសអំពីការបាត់ខ្លួនក៏ដោយ ក៏មានអានុភាពប្រតិសកម្មទៅលើការចាត់ចែងទ្រព្យសម្បត្តិរួម ដែល **កញ្ញា** បានធ្វើនោះដែរ ប៉ុន្តែ **សៅ** មានកាតព្វកិច្ចសាមគ្គីភាពក្នុងការសងបំណុលរួមដែលនៅសល់ជាមួយនឹង **កញ្ញា**។

ក្រោយពេលដែលរបបសន្តតិកម្មបានចាប់ផ្តើម មតកជនបានបន្សល់ទុកនូវមត៌ក និងករណីយកិច្ចមួយចំនួនដល់សន្តតិជនដើម្បីទទួលបន្ត ប៉ុន្តែសន្តតិជនបែរជាក្លាយជាអសមត្ថជន (ជនស្ថិតក្រោមអាណាព្យាបាលទូទៅ ឬជនស្ថិតក្រោមហិតូបត្ថម្ភ) ដោយហេតុថាគាត់បានទទួលរងនូវសម្ពាធផ្លូវចិត្ត និងស្មារតីធ្ងន់ធ្ងររហូតមិនអាចវិនិច្ឆ័យ ឬអាចយល់ដឹង និងវិនិច្ឆ័យបានតិចតួចបំផុតអំពីលទ្ធផលតាមផ្លូវច្បាប់ នៃសកម្មភាពរបស់ខ្លួន តុលាការមានសិទ្ធិយកទ្រព្យសកម្មរបស់មតកជនមកទូទាត់បំណុល។

**ឧទាហរណ៍ ៖** ក្រោយពេលដែលប្ដីបានស្លាប់ ប្រពន្ធក៏បានក្លាយទៅជាមនុស្សឆ្កួត ប៉ុន្តែប្ដីបានជំពាក់បំណុលគេជាច្រើន ដោយហេតុថា ប្រពន្ធត្រូវបានក្លាយជាជនដែលត្រូវបានគេកម្រិតសមត្ថភាព ដូចនេះតុលាការជាអ្នកចេញសេចក្ដីសម្រេចក្នុងការចាត់ចែងទ្រព្យសកម្មភាពរបស់មតកជន ដើម្បីទូទាត់បំណុលរបស់មតកជន ដែលជាបទបញ្ញត្តិទូទៅទាក់ទងនឹងការរឹបអូសបំណុល។

ក្នុងករណីដែលតុលាការរកឃើញថាសហព័ទ្ធដែលជាសន្តតិជននោះ គឺជាបុគ្គលដែលសម្លាប់មតកជន ឬបានក្លែងលិខិតមតកសាសន៍ស្ដីពីសន្តតិកម្មរបស់មតកជន សហព័ទ្ធនោះត្រូវបានចាត់ទុកជាអភ័ព្វបុគ្គលនៃសន្តតិកម្ម។[70] ដូច្នេះសហព័ទ្ធនោះពុំអាចទទួលនូវមត៌ករបស់មតកជននោះទេ ដោយឡែកចំពោះបំណុលរួមវិញ គឺតុលាការនឹងធ្វើការរឹបអូសទ្រព្យរបស់មតកជន ដើម្បីធ្វើការទូទាត់ទៅម្ចាស់បំណុល។ ប៉ុន្តែចំពោះបំណុលដោយឡែកវិញ គឺសហព័ទ្ធដែលនៅរស់នោះត្រូវតែទទួលខុសត្រូវដោយខ្លួនឯង ពុំអាចយកទ្រព្យរួម ទៅធ្វើការដោះស្រាយបាននោះទេ។

[70] មាត្រា ១១៥០ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ។

# សេចក្តីសន្និដ្ឋាន

យោងតាមទិដ្ឋភាពជាក់ស្តែងក្នុងសង្គមបច្ចុប្បន្ន ដែលអាចកត់សម្គាល់ក្រោយពេលសិក្សាស្រាវជ្រាវលើប្រធានបទខាងលើបានបង្ហាញឱ្យឃើញថា ការបញ្ញត្តិអំពីបំណុលរួម និងបំណុលដោយឡែករបស់សហព័ទ្ធតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា គឺនៅតែមានចំណុចខ្វះខាតមួយចំនួននៅឡើយ ដែលពុំទាន់បានចងក្រងឱ្យលម្អិត និងបកស្រាយឱ្យបានក្បោះក្បាយក្នុងករណីមួយចំនួនដែលត្រូវធ្វើការសិក្សាស្វែងយល់បន្ថែម។ តាមការអនុវត្តជាក់ស្តែង គេសង្កេតឃើញថា ក្រោយពេលលែងលះ សហព័ទ្ធតែងតែមានវិវាទលើការបែងចែកទ្រព្យសម្បត្តិរួម ដោយភាគច្រើនក្នុងករណី ដែលសហព័ទ្ធម្ខាងបានធ្វើការចាត់ចែងទ្រព្យសម្បត្តិដោយឡែករបស់ខ្លួន ហើយបានយកតម្លៃតបនៃទ្រព្យដោយឡែកនោះមកដាក់បញ្ចូលទៅក្នុងទ្រព្យរួមវិញ។ ចំណុចនៃវិវាទជាច្រើនគឺស្ថិតនៅលើទំហំនៃការបរិច្ចាករបស់សហព័ទ្ធតែម្ខាង ព្រោះពេលខ្លះសហព័ទ្ធម្ខាងបានដាក់ចំណែកនៃទ្រព្យដោយឡែកតិចជាងសហព័ទ្ធម្ខាងទៀត លុះពេលទាមទារបែងចែកទ្រព្យសម្បត្តិរួម គឺស្នើសុំឱ្យតុលាការអនុវត្តតាមគោលការណ៍ច្បាប់ ដែលត្រូវបែងចែកជាពីរចំណែកស្មើៗគ្នា។

ចន្លោះច្បាប់ត្រង់ចំណុចនេះ បានបង្កើតជាវិវាទយ៉ាងច្រើន ហើយក៏បានជះឥទ្ធិពលផងដែរដល់ការអនុវត្តកាតព្វកិច្ចលើបំណុលរបស់សហព័ទ្ធ ព្រោះម្ចាស់បំណុលអាចបង្ខំឱ្យកូនបំណុលអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យា ហើយបើកូនបំណុលមិនអាចអនុវត្តកាតព្វកិច្ចបានទេ នោះម្ចាស់បំណុលអាចរឹបអូសទ្រព្យរបស់កូនបំណុលបាន។ បញ្ហាជាច្រើនកើតមានឡើងក្រោយពេលលែងលះ ដោយហេតុថាតុលាការត្រូវបែងចែកទ្រព្យសម្បត្តិផង និងបំណុលរបស់សហព័ទ្ធផង ដែលរាប់បញ្ចូលទាំងបំណុលរួម និងបំណុលដោយឡែក។ បើយោងទៅតាមច្បាប់ បំណុលរួមត្រូវយកទ្រព្យសម្បត្តិរួមមកឆ្លើយតបទៅនឹងបំណុល ប៉ុន្តែប្រសិនបើទ្រព្យសម្បត្តិរួមមិនអាចកំណត់បានច្បាស់នោះទេ ពិតណាស់វានឹងបង្កឱ្យមានជម្លោះនៃការទាមទារកើតឡើង ហើយវាក៏អាចប៉ះពាល់ដល់ប្រយោជន៍របស់តតិយជនផងដែរ។

ម្យ៉ាងវិញទៀត ទោះបីជារដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលជាច្បាប់កំពូលរបស់រដ្ឋ បានកំណត់ថាការងារមេផ្ទះមានតម្លៃស្មើគ្នាទៅនឹងកម្រៃដែលបានមកពីការងារធ្វើនៅក្រៅផ្ទះក៏ដោយ ប៉ុន្តែចំពោះករណីដែលសហព័ទ្ធម្ខាងជាពាណិជ្ជករ ហើយបានយកទ្រព្យសម្បត្តិទៅធ្វើការវិនិយោគ ទោះបីជាទទួលបានការព្រមព្រៀងពីសហព័ទ្ធម្ខាងទៀត ប៉ុន្តែនៅពេលដែលមានការលែងលះ តុលាការនៅតែធ្វើការបែងចែកបំណុលរួមជាពីរចំណែកស្មើៗគ្នា ដូចនេះក្នុងករណីដែលសហព័ទ្ធម្ខាងជាស្ត្រីមេផ្ទះ គាត់អាចនឹងជួបហានិភ័យមួយចំនួន ក្រោយពេលដែលមានការលែងលះ ព្រោះគាត់អាចនឹងពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការឆ្លើយតបទៅនឹងបំណុលរួម ព្រោះរយៈពេលកន្លងមកសហព័ទ្ធដែលជាស្ត្រីមេផ្ទះនោះមិនបានបំពេញការងារដើម្បីស្វែងរកប្រាក់ចំណូលនោះទេ ដោយផ្តោតទៅលើកិច្ចការនៅក្នុងផ្ទះទាំងស្រុង។

ទន្ទឹមនឹងភាពរីកចម្រើន នៃក្របខណ្ឌគតិយុត្តនៃការគ្រប់គ្រងទៅលើសិទ្ធិ និងករណីយកិច្ចរបស់សហព័ទ្ធលើបំណុលនៅកម្ពុជា ក្នុងការអនុវត្តជាក់ស្តែងនៅមិនទាន់បានពេញលេញទេ។ បញ្ហាចោទទីមួយ គឺក្រោយពេលលែងលះ សហព័ទ្ធនៅតែមានភាពចម្រូងចម្រះទៅលើការបែកចែកទ្រព្យសម្បត្តិរួម ដែលពាក់ព័ន្ធនឹងទំហំនៃការបម្លែងទ្រព្យដោយឡែកទៅជាទ្រព្យរួមក្រោយពេលរៀបអាពាហ៍ពិពាហ៍។ ឬសគល់នៃបញ្ហានេះ គឺបណ្តាលមកពីសហព័ទ្ធមិនបានជ្រាបច្បាស់អំពីប្រព័ន្ធទ្រព្យសម្បត្តិដែលមានចែងនៅក្នុងច្បាប់។ បញ្ហាចោទទីពីរនោះគឺការបែងចែកបំណុលរួមចំពោះសហព័ទ្ធដែលជាស្ត្រីមេផ្ទះ នៅពុំទាន់មានតុល្យភាពនៅឡើយ ក្នុងការដោះស្រាយបំណុលដែលបន្សល់ទុកក្រោយពេលលែងលះ។

# អនុសាសន៍

ដើម្បីធ្វើការឆ្លើយតបជាមួយនឹងបញ្ហាចោទ ដើលកើតមានឡើងនៅជុំវិញការអនុវត្តសិទ្ធិ និងករណីយកិច្ចរបស់សហាព័ទ្ធលើបំណុល ឱ្យកាន់តែមានភាពប្រសិទ្ធិភាព និងតម្លាភាពតាមផ្លូវច្បាប់ យើងខ្ញុំសូមលើកឡើងនូវដំណោះស្រាយមួយចំនួនដូចខាងក្រោម ៖

**ក.ឆ្លើយតបនឹងបញ្ហានៃការបែងចែកទ្រព្យសម្បត្តិរបស់សហាព័ទ្ធ**

- ចំពោះការយកទ្រព្យដោយឡែក ទៅដាក់បញ្ចូលជាទ្រព្យរួម សហាព័ទ្ធគួរគប្បីមានកិច្ចសន្យាដោយឡែកមួយដោយបញ្ជាក់ពីទំហំនៃការបរិច្ចាករបស់សហាព័ទ្ធម្ខាងៗ ជាពិសេសចំពោះអចលទ្រព្យ ព្រោះកន្លងមកវិវាទកើតមានឡើង ក្រោយពេលដែលអចលនទ្រព្យដែលបានមកពីការដាក់បញ្ចូលនូវទ្រព្យដោយឡែករាងៗខ្លួននោះបានឡើងថ្លៃ ហើយក្រោយពេលលែងលះ សហាព័ទ្ធទាមទារទៅតាមចំណែករបស់ខ្លួន ដូច្នេះហើយប្រសិនបើសហាព័ទ្ធបានកំណត់ពីទំហំនៃចំណែករបស់ខ្លួននៅក្នុងកិច្ចសន្យារួចហើយ តុលាការអាចពិចារណាធ្វើការបែងចែងទៅតាមការបរិច្ចាករបស់ភាគីនីមួយៗ។ ក្រោយពេលដែលទ្រព្យសម្បត្តិបានបែងចែកច្បាស់លាស់ហើយ កាតព្វកិច្ចលើបំណុលរបស់សហាព័ទ្ធ ក៏អាចអនុវត្តបានរលូនផងដែរ។

**ខ. ឆ្លើយតបទៅនឹងបញ្ហាអនុវត្តកាតព្វកិច្ចបំណុលចំពោះសហាព័ទ្ធជាពាណិជ្ជករ**

- ចំពោះសហាព័ទ្ធដែលជាពាណិជ្ជករអាចជ្រើសរើសទម្រង់ក្រុមហ៊ុន ជាក្រុមហ៊ុនមហាជន ឬក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ដើម្បីអាចកម្រិតនូវការទទួលខុសត្រូវរបស់ខ្លួន ព្រោះការទទួលខុសត្រូវមានកម្រិតគឺត្រឹមតែចំណែកដែលខ្លួនបានដាក់ភាគហ៊ុនប៉ុណ្ណោះ ។ ម្យ៉ាងវិញទៀតសហាព័ទ្ធ គួរគប្បីចុះបញ្ជីបង្កើតក្រុមហ៊ុន ដើម្បីអាចកាត់បន្ថយនូវហានិភ័យក្នុងការយកទ្រព្យសម្បត្តិរួមរបស់ខ្លួន ទៅឆ្លើយតបនឹងបំណុលរបស់ក្រុមហ៊ុននោះ។

# ឯកសារយោង


## ❖ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។
- ច្បាប់ស្តីពីសញ្ជាតិ, លេខ នស/រកម/០៦១៨/០០៨, ២១ មិថុនា ២០១៨។
- ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១។
- ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។
- ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។
- ច្បាប់ស្តីពីឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦, ២១ តុលា ២០០៦។
- ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥។
- ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម, លេខ នស/រកម/០៦៩៥/០៤, ១៨ វិច្ឆិកា ១៩៩៩។
- អនុក្រឹត្យស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស, លេខ ១៨៣ អនក្រ.បក, ០៣ វិច្ឆិកា ២០០៨។

## ❖ ច្បាប់ដែលត្រូវបាននិរាករណ៍

- ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ២០ សីហា ២០០១។
- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ក្រ, ១៧ កក្កដា ១៩៨៩។

## ❖ សៀវភៅដែលបានបោះពុម្ពផ្សាយ

- ក្រសួងយុត្តិធម៌, ២០០៩, សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ១, ភ្នំពេញ ៖ ក្រសួងយុត្តិធម៌។
- ក្រសួងយុត្តិធម៌, ២០០៩, សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៥, ភ្នំពេញ ៖ ក្រសួងយុត្តិធម៌។
- ក្រសួងយុត្តិធម៌, ២០០៩, សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦, ភ្នំពេញ ៖ ក្រសួងយុត្តិធម៌។

## ❖ គេហទំព័រ

- សេង ឌីណា, ការគ្រប់គ្រង ចាត់ចែង និងបែងចែកទ្រព្យសម្បត្តិប្តីប្រពន្ធ, ១៣ ខែ ធ្នូ ឆ្នាំ ២០១២, គេហទំព័រ https://www.rfi.fr/km/marriage-and-property-ownership?fbclid=IwAR3QGIRNBX4GJd0ANPTlojt9nSzFkJKAh9V0qbiKxwj8sM8f2STCu33ceqY, ចូលទស្សនាថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២១។

- កញ្ញាមេធាវី ទ្រី ស្រីល័ក្ខណ និងកញ្ញា សរ ម៉ារីណា, ការទទួលខុសត្រូវរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត, ២៣ ធ្នូ ២០១៨, គេហទំព័រ http://freshnewsasia.com/index.php/en/localnews/108060-2018-12-23-03-20-01.html, ចូលទស្សនាថ្ងៃទី១០ ខែឧសភា ឆ្នាំ ២០២១ ។

# ឧបសម្ព័ន្ធទី១
# សេចក្តីសម្រេចរបស់តុលាការ

23/6

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមរដ្ឋប្បវេណី**

-លេខ: ១១១១ "ឃ"

-ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០

-សំណុំរឿងរដ្ឋប្បវេណីលេខ: ១៨២៦ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ៩ និង ០០ នាទីព្រឹក លើសំណុំរឿងរដ្ឋប្បវេណីលេខ ១៨២៦ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩ ដោយមានសមាសភាព៖

**ចៅក្រមជំនុំជម្រះ**

-លោក ជាចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

-លោកស្រី ជាក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

រវាងដើមចោទឈ្មោះ មុខរបរលក់ដូរ មានទីលំនៅ ឪពុកឈ្មោះ ម្តាយឈ្មោះ ប្តីឈ្មោះ ានកូន០២នាក់។

ដោយមានលោក ជាមេធាវីតំណាងដោយអាណត្តិ

និងចុងចម្លើយឈ្មោះ មុខរបរលក់ដូរ មានទីលំនៅ ឪពុកឈ្មោះ ម្តាយឈ្មោះ ប្រពន្ធឈ្មោះ មានកូន០២នាក់។

ដោយមានលោក ជាមេធាវីតំណាងដោយអាណត្តិ

## I.អង្គហេតុ និងចំណុចវិវាទ

**១.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ**

១.១.ឲ្យឈ្មោះ និងឈ្មោះ លែងលះគ្នាតាមច្បាប់។

១.២.សុំសិទ្ធិអំណាចមេបាលើកូនស្រីឈ្មោះ

១.៣.សុំបែងចែកទ្រព្យសម្បត្តិរួម ក្រោយពេលទូទាត់បំណុលរួចចប់សព្វគ្រប់។

**២.ការពន្យល់ត្រួសៗអំពីរឿងក្តី**

ដើមចោទឈ្មោះ និងចុងចម្លើយឈ្មោះ បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ត្រឹមត្រូវតាមផ្លូវច្បាប់។ ក្នុងអំឡុងរស់នៅជាមួយគ្នា ដើមចោទ និងចុងចម្លើយមានកូន០២នាក់ ឈ្មោះ និង ដោយសារដើមចោទ និងចុងចម្លើយចេះតែមានទំនាស់ក្នុងគ្រួសារ មិនអាចសម្របសម្រួលគ្នាបាន ទើបធ្វើឲ្យអស់មនោសញ្ចេតនាក្នុងការរួមរស់ជាប្តីប្រពន្ធរហូតឈានដល់ការដាក់ពាក្យបណ្តឹងសុំលែងលះមកតុលាការ។ ចំពោះទ្រព្យសម្បត្តិរួម និងបំណុល សុំឲ្យតុលាការបែងចែកតាមការព្រមព្រៀង។

៣.អង្គហេតុដែលអះអាងដោយដើមចោទ

ដើមចោទឈ្មោះ  បានធ្វើសេចក្ដីថ្លែងការណ៍ថា: ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយប្ដី កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០០០ និងបានចុះ ________________ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០០០ ចេញដោយអភិបាលខណ្ឌឫស្សីកែវ ក្នុងអំឡុងរស់នៅជាមួយគ្នាមានសេចក្ដីសុខធម្មតា ដោយបង្កើតបានកូន ០២នាក់ ឈ្មោះ  លុះមកដល់ខែ តុលា ឆ្នាំ២០១៨ ខ្លួននិងប្ដីចាប់ផ្ដើមមានបញ្ហាជាមួយគ្នាជាញឹកញាប់ ដោយសារប្ដីចេះតែរករឿងខ្លួនមិនចេះចប់មិនចេះហើយ និងបានចោទប្រកាន់ខ្លួនថាមិនស្មោះត្រង់ជាមួយគាត់ តែជាក់ស្ដែងគាត់ទេដែលមានទំនាក់ទំនងខាងក្រៅ ខ្លួនតែងតែធ្វើការផ្សះផ្សា និងផ្ដល់ឱកាសឲ្យគាត់រហូត ប៉ុន្តែគាត់មិនបានធ្វើការកែខ្លួននោះទេ គាត់នៅតែលួចលាក់មានស្រី និងបានដើរបរិហាខ្លួនរហូត ទើបធ្វើឲ្យខ្លួនអស់ចិត្តពីប្ដី ឈានដល់ការប្ដឹងសុំលែងលះតែម្ដង។

ខ្លួននៅតែប្ដឹងសុំលែងលះប្ដីឈ្មោះ  ដដែល ព្រោះពុំអាចសះជាគ្នាបានទេ ហើយខ្លួន និងប្ដីក៏បានព្រមព្រៀងគ្នាលែងលះដោយស្ម័គ្រចិត្ត នឹងបែងចែកទ្រព្យសម្បត្តិគ្នាផងដែរ។ សំណូមពរ: សុំឲ្យតុលាការចេញសាលក្រមឲ្យខ្លួនបានលែងលះប្ដី និងផ្ដល់សិទ្ធិអំណាចមេបាលើកូនឈ្មោះ  មកឲ្យខ្លួនតាមកិច្ចព្រមព្រៀងលែងលះដោយស្មគ្រចិត្ត ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០, កិច្ចព្រមព្រៀងបំពេញបន្ថែម ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០២០ និងបែងចែកទ្រព្យសម្បត្តិតាមការព្រមព្រៀង ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ រួមមាន:

**១.ខ្លួនសុំសិទ្ធិគ្រប់គ្រងនូវទ្រព្យសម្បត្តិដូចខាងក្រោម:**

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ

-រថយន្តម៉ាក

-អាជីវកម្មលក់គ្រឿងសំណង់

**២.ខ្លួនសុខចិត្តប្រគល់ឲ្យប្ដីឈ្មោះ  នូវ:**

-ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ

